ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំង
អំពើជួញដូរមនុស្ស

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ
លេខៈ ១៧៥/១៦ ...

# របាយការណ៍បូកសរុប
# សកម្មភាពនិងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទប្រចាំត្រីមាសទី៣ និងទិសដៅត្រីមាសទី៤ ឆ្នាំ ២០១៦

( គិតចាប់ពីថ្ងៃទី ០១ ខែ កក្កដា ដល់ថ្ងៃទី ៣១ ខែកញ្ញា ឆ្នាំ២០១៦ )

## ១. សភាពការណ៍ទូទៅ

នៅត្រីមាសទី៣ ឆ្នាំ២០១៦ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) បានបំពេញតួនាទីតាមមុខងាររបស់ខ្លួនដែលមានចែងក្នុងព្រះរាជក្រឹត្យ អនុក្រឹត្យ សេចក្តីសម្រេច និងប្រកាស ដោយមានកិច្ចសហប្រតិបត្តិការរួមគ្នាជាមួយក្រសួង ស្ថាប័នពាក់ព័ន្ធទាំងថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងអន្តរជាតិ រួមទាំងអង្គការមិនមែនរដ្ឋាភិបាលជាដៃគូជាតិ និងអន្តរជាតិ។

ដោយឡែក សភាពការណ៍បទល្មើសជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅតែជាបញ្ហាដែលត្រូវយកចិត្តទុកដាក់។ ផ្អែកតាមរបាយការណ៍ ដែលគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សទទួលបានពីក្រសួង ស្ថាប័នពាក់ព័ន្ធ លេខាធិការដ្ឋាននៃគណៈកម្មាធិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សថ្នាក់ក្រោមជាតិ រកឃើញថាភាពរងគ្រោះនៅតែកើតមាន ក្នុងចំណោមទេសន្តរប្រវេសន៍ស្វែងរកការងារ និងការស្វែងរកគូស្រករនៅក្រៅប្រទេស ។ ក្នុងចំណោមជនទេសន្តរប្រវេសន៍ដែលកំពុងស្នាក់នៅក្រៅប្រទេស ទាំងស្របច្បាប់ និងមិនស្របច្បាប់ត្រូវបានរងគ្រោះ និងត្រូវបានចាប់បញ្ជូនត្រឡប់មកកម្ពុជាវិញជាបន្តបន្ទាប់ មួយចំនួនបានត្រឡប់មកផ្ទះវិញដោយខ្លួនឯង និងខ្លះទៀតបាត់ដំណឹង។ ទាំងអស់នេះគឺជាបញ្ហាដែលគណៈកម្មាធិការជាតិ ត្រូវរួមសហការព្យាយាមបង្ការ បង្ក្រាប និងដោះស្រាយរួមគ្នា។

អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ បានពង្រឹងកិច្ចសហការជាមួយដៃគូជាតិ និងអន្តរជាតិពាក់ព័ន្ធដើម្បីបង្កើនកិច្ចខិតខំប្រឹងប្រែង ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងជំរុញបន្ថែមទៀត និងសម្របសម្រួលរវាងសមាជិក ក្នុងក្រុមការងារអន្តរក្រសួង ស្ថាប័នព្រមទាំងរាជធានី-ខេត្ត ដើម្បីរកដំណោះស្រាយបញ្ហាប្រឈមនានា ដោយត្រៀមចុះវាយតម្លៃការអនុវត្តផែនការជាតិ២០១៤-២០១៨ ពាក់កណ្តាលអណត្តិទី១ ដើម្បីកែលម្អសកម្មភាពក្នុងដំណាក់កាលទី២ និងត្រៀមបណ្តុះបណ្តាល «**គោលការណ៍ណែនាំ ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដើម្បីផ្តល់សេវាសមស្រប**» ដល់ប្រតិបត្តិករថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងមន្ត្រីស្ថានទូតកម្ពុជា ប្រចាំនៅប្រទេសគោលដៅ ដែលមានពលករកម្ពុជា ដើម្បីអនុវត្តព្រមគ្នា តាមគោលការណ៍តែមួយ។

ខាងក្រោមនេះ ជាទិន្នន័យដែលទទួលបានពីក្រុមការងារអនុវត្តន៍ច្បាប់ ដែលដឹកនាំដោយអគ្គស្នងការនគរបាលជាតិ, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា, និងរាជធានី/ខេត្ត ព្រមទាំងអង្គការដៃគូនានា និងការស្រាវជ្រាវព័ត៌មានរបស់អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ដែលសរុបបានជាលទ្ធផលដូចខាងក្រោម៖

## ២.លទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រីមាសទី៣

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៦នេះ គណៈកម្មាធិការជាតិ និងក្រោមជាតិ បានបន្តយកចិត្តទុកដាក់ អនុវត្តផែនការសកម្មភាព និងទិសដៅការកិច្ចរបស់ខ្លួន ដោយពង្រឹងកិច្ចសហប្រតិបត្តិការរវាងបណ្ដាក្រសួង ស្ថាប័ន មន្ទីរ អង្គភាពពាក់ព័ន្ធនិងអង្គការមិនមែនរដ្ឋាភិបាលជាតិ អន្តរជាតិ បានធ្វើឱ្យសម្រេចនូវលទ្ធផលដូចខាងក្រោម៖

- ជនរងគ្រោះដោយអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ត្រូវបានរកឃើញជាច្រើនករណី ជាពិសេសតាមរូបភាពទេសន្តរប្រវេសន៍ស្វែងរកការងារ ទេសន្តរប្រវេសន៍ស្វែងរកគូស្រករនៅក្រៅប្រទេស តាមប្រព័ន្ធស្របច្បាប់ នឹងមិនស្របច្បាប់ ។
- ជនរងគ្រោះត្រូវបានសង្គ្រោះជាបន្តបន្ទាប់ ខ្លះត្រូវចាប់ខ្លួនបញ្ជូនមកកម្ពុជាវិញ ខ្លះមកដោយខ្លួនឯងឬក្រុមហ៊ុន ដោយមានស្ថានទូត និងអង្គការដៃគូនៅក្រៅប្រទេសជួយសម្របសម្រួលកិច្ចសហការជាមួយអាជ្ញាធរ និងសមត្ថកិច្ចនៃប្រទេសដែលមានជនរងគ្រោះកម្ពុជាស្ថិតនៅ ។
- ការឆ្លើយតបនៅមិនទាន់មានលក្ខណៈជាប្រព័ន្ធ ហើយនៅមានបញ្ហាសេសសល់ជាច្រើនដែលត្រូវការខិតខំបន្តទៀត ដូចជាខ្វះការតាមដានស្ថានភាពជនរងគ្រោះបន្ត បន្ទាប់ពីត្រូវបានបញ្ជូនត្រឡប់ទៅគ្រួសារ ឬសហគមន៍ ការសិក្សាអំពីការត្រឡប់ទៅធ្វើទេសន្តរប្រវេសន៍ជាថ្មី ការស្រាវជ្រាវលើបណ្ដឹងរបស់ជនរងគ្រោះដើម្បីទាមទារយុត្តិធម៌ និងសំណងបដិទានជាដើម ។

### ២.ក. ការងារផ្នែកច្បាប់ គោលនយោបាយជាតិ និងបទដ្ឋានគតិយុត្តពាក់ព័ន្ធ

នៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៦នេះ ដើម្បីបំពេញឲ្យសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស គណៈកម្មាធិការជាតិ គ.ជ.ប.ជ បានបន្តអនុវត្តអនុសាសន៍ និងវិធានការ របស់រាជរដ្ឋាភិបាល មួយចំនួនដូចខាងក្រោម៖

### ២.ខ-ការអនុវត្តយុទ្ធសាស្ត្រប្រឆាំងការជួញដូរមនុស្ស

#### ២.ខ.១-ការងារបង្ការ ទប់ស្កាត់

ការផ្សព្វផ្សាយអប់រំ បំផុសការយល់ដឹងតាមគ្រប់រូបភាព ត្រូវបានធ្វើឡើងតាមរយៈវេទិកាសាធារណៈ កិច្ចប្រជុំ សិក្ខាសាលា និងតាមប្រព័ន្ធផ្សព្វផ្សាយនានា រួមមានវិទ្យុ ទូរទស្សន៍ ប្រព័ន្ធបណ្ដាញសង្គម យ៉ាងទូលំទូលាយនៅគ្រប់ទីកន្លែង ដល់មន្ត្រីរាជការ ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សាលារៀន និងប្រជាពលរដ្ឋតាមបណ្ដាឃុំ សង្កាត់ ភូមិ និងសហគមន៍នានា ។

##### ២.ខ.១.១. ការបង្ការ ទប់ស្កាត់ តាមរយៈការអប់រំផ្សព្វផ្សាយ

សរុបការងារផ្សព្វផ្សាយអប់រំក្នុងត្រីមាសទី៣ ឆ្នាំ២០១៦នេះ ទាំងនៅថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ ស្ថាប័នពាក់ព័ន្ធ អាជ្ញាធរ និងសមត្ថកិច្ច បានសហការជាមួយអង្គការដៃគូធ្វើការផ្សព្វផ្សាយជាសាធារណៈទៅតាមគោលដៅបានចំនួន១០,០៨៥លើក មានមនុស្សចូលរួមចំនួន៦១៤,៦៨៣នាក់ បើប្រៀបធៀបត្រីមាសទី៣ ឆ្នាំ២០១៥

មានអ្នកចូលរួមត្រឹមចំនួន៣,២៤៣នាក់ មានការកើនឡើងចំនួន៦៨៤២នាក់ ស្មើនឹង ២១១.០៤% ស្រីចំនួនសរុប៣១០,១៧៧នាក់)។

ក. **ការអប់រំផ្សព្វផ្សាយ ដោយក្រសួង ស្ថាប័នៈ**

***ក.១. ការផ្សព្វផ្សាយ អប់រំផ្ទាល់ៈ***

សរុបការងារផ្សព្វផ្សាយអប់រំផ្ទាល់ ច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទរបស់ក្រសួងស្ថាប័ន រហូតដល់ថ្នាក់ខេត្ត ក្រុង ស្រុក ភូមិ ឃុំ បានចំនួន៤៣២លើក មានមនុស្សចូលរួមចំនួន២៤,៣៧៨នាក់ (ស្រីចំនួន១១,៩៤០នាក់)។

- នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ និងស្នងការដ្ឋាននគរបាលខេត្តៈ ស្វាយរៀង, កំពង់ស្ពឺ, និងកំពង់ចាម, បានផ្សព្វផ្សាយ ច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ក្នុងកម្មវិធីអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់ម្ចាស់អាជីវកម្ម អាជ្ញាធរមូលដ្ឋានប្រជាពលរដ្ឋ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្សចំនួន៣៩៧លើក មានប្រជាពលរដ្ឋចូលរួមចំនួន២៤,២០៨នាក់ (ស្រីចំនួន១១,៨៧៧នាក់)។

***ក.២. ការផលិត និងចែកផ្សាយសម្ភារអប់រំ និងផ្សព្វផ្សាយៈ***

- ខេត្តឧត្តរមានជ័យ ចុះបិទផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទនូវមាត្រាច្បាប់នីមួយៗតាមក្លឹបកម្សាន្ត និងការ៉ាអូរខេជាប្រចាំ ។

***ក.៣. ការផ្សព្វផ្សាយតាមវិទ្យុ និងទូរទស្សន៍ៈ***

ការងារផ្សព្វផ្សាយច្បាប់តាមវិទ្យុ និងទូរទស្សន៍ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ របស់ក្រសួងស្ថាប័ន រហូតដល់ថ្នាក់ខេត្ត ក្រុង ស្រុក ភូមិ ឃុំ បានចំនួន៣៥លើក មានមនុស្សចូលរួមចំនួន១៧០នាក់ (ស្រីចំនួន៦៣នាក់)។

- ខេត្តកំពត ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាល បានចាក់ផ្សាយឌីស "ដើងមេឃនៅឯណា" បានចំនួន៣លើក មានអ្នកចូលរួមចំនួន១០៨នាក់ ស្រីចំនួន២៧នាក់(នៅស្រុកបន្ទាយមាស និងស្រុកអង្គរជ័យ)។
- ខេត្តកំពង់ចាម លោកស្រី ស្នងការរងទទួលបន្ទុកបានចូលរួមជាអធិបតី និងធ្វើជាវាគ្មិននៅក្នុងកម្មវិធីវិទ្យុលើប្រធានបទ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន០១លើក នៅស្ថានីយ៍វិទ្យុទន្លេអុំ ៨៩.៧០MZ ស្ថិតនៅភូមិបឹងកុក២ សង្កាត់បឹងកុក ក្រុងកំពង់ចាម ។
- ខេត្តសៀមរាប ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានធ្វើការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅប៉ុស្តិ៍វិទ្យុនគរធំ បានចំនួន២៨លើក និងបានចុះល្បាតពេលយប់នៅតាមផ្សាររាត្រីមាត់ស្ទឹង និងតាមសួនច្បារមុខសណ្ឋាគារហ្វ្រេនអង្គរ ។
- បាត់ដំបង ការិយាល័យប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្តៈ បានចូលរួមធ្វើជាវាគ្មិននៅវិទ្យុជាតិចម្ការចេក FM៩២.៧0MHz ក្នុងកម្មវិធី សន្ទនាមតិពន្លឺ មូលដ្ឋាន ក្រោមប្រធានបទ " បញ្ហាការធ្វើចំណាកស្រុក " រៀបចំដោយវិទ្យុជាតិចម្ការចេក ធ្វើនៅក្នុង ៨៦

បរិវេណវត្តអូរមុនី ភូមិអូរមុនី ឃុំអន្លង់វិល ស្រុកសង្កែ ខេត្តបាត់ដំបង បានចំនួន០៣លើក ដែលមានប្រជាពលរដ្ឋចូលរួមចំនួន៦២នាក់ ស្រីចំនួន៣៦នាក់ ។

ខ. <u>ការអប់រំផ្សព្វផ្សាយ តាមការបញ្ជ្រាបខ្លឹមសារទៅក្នុងវេទិកាសាធារណៈស្តីពីភូមិឃុំមានសុវត្ថិភាព៖</u>

- បានដាក់បញ្ចូលខ្លឹមសារស្តីពីការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងកលល្បិចជនល្មើស ទៅក្នុងវេទិកាសាធារណៈនៃការអនុវត្តគោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព ដល់អាជ្ញាធរមូលដ្ឋាន និងប្រជាពលរដ្ឋបានចំនួន៩,៦៥៣លើក មានមនុស្សចូលរួមសរុបចំនួន ៥៩០,៣០៥នាក់ ស្រីចំនួន២៩៨,២៣៧នាក់ ដែលមានតួលេខក្នុងតារាងខាងក្រោម៖

***តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈវេទិកាគោលនយោបាយភូមិឃុំមានសុវត្ថិភាព (ទិន្នន័យពីបណ្តារាជធានី-ខេត្ត) ៖***

តារាងទិន្នន័យនៃការអប់រំផ្សព្វផ្សាយតាមរយៈវេទិកាគោលនយោបាយភូមិឃុំមានសុវត្ថិភាព ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៦

| ល.រ | ក្រ. ស្ថាប័ន | ការផ្សព្វផ្សាយ (ខ.១) | | | វេទិកាសាធារណៈ(ខ.២) | | |
|---|---|---|---|---|---|---|---|
| | រាជធានី-ខេត្ត | ចំនួនដង/លើក | សរុបអ្នកចូលរួម | ចំនួនស្ត្រី | ចំនួនដង/លើក | សរុបអ្នកចូលរួម | ចំនួនស្ត្រី |
| ១ | ព្រះសីហនុ | ៣២ | ១,៣៤៧ | ៥៩៧ | ១២ | ១,០០០ | ៣៧៨ |
| ២ | កំពត | ៩ | ៦៨៤ | ៣៥៩ | ១៧ | ១,៤១៩ | ៦៧០ |
| ៣ | កែប | ២ | ៣០០ | ១៩០ | ៦៤ | ១០,១១៦ | ៥,៤៤៦ |
| ៤ | តាកែវ | ២០៥ | ៦០,១៧២ | ៥,១៦២ | ២,០៨០ | ៦,០០២ | ២,៣២៣ |
| ៥ | កណ្តាល | ១៨២ | ១៥,១៨១ | ១១,០២៦ | ២,៦៥៤ | ១៤,៥៦១ | ៧,៧២១ |
| ៦ | ស្វាយរៀង | ១៥ | ៧៤០ | ៣៣០ | ៥២២ | ៣១,០០៨ | ១៥,១៨៨ |
| ៧ | ព្រៃវែង | ៥ | ៥០៩ | ៣៥៨ | | | |
| ៨ | កំពង់ស្ពឺ | ២០ | ២,៧៧២ | ១,៦៤២ | | | |
| ៩ | កោះកុង | ៤ | ១០៨ | ៨៤ | ២៨ | ៨២៥ | ៦៤៣ |
| ១០ | ឧត្តរមានជ័យ | ៣៧ | ៥,៥២៩ | ២,៨២៧ | | | |
| ១១ | បាត់ដំបង | ៦៦៨ | ៤៥,៩៧៥ | ២១,៩៣៣ | ១៩៤ | ២០,១៧២ | ១០,២៤៤ |
| ១២ | ពោធិ៍សាត់ | ៣៥២ | ៣៨,១២៩ | ២០,២៧៨ | ៣៣ | ១,៨៩៣ | ៨៩២ |
| ១៣ | កំពង់ឆ្នាំង | ១,០៤៥ | ១២៥,៦៩១ | ៨០,៨៣៣ | ១,០៥៧ | ១៤១,០៨៩ | ៧៧,២៩៩ |
| ១៤ | ព្រះវិហារ | ២៥ | ៨,២២១ | ៤,១៨០ | ១៨៩ | ៤៤,១២១ | ២០,៧៦១ |
| ១៥ | សៀមរាប | ៨២ | ៤,៩៧៦ | ៣,០៧៤ | ២ | ១០៨ | ៦២ |
| ១៦ | កំពង់ធំ | ៨ | ១,៥៨៩ | ៩៥៧ | | | |
| ១៧ | រតនគិរី | ៨ | ៣៧៦ | ១៦៣ | ៦៩ | ៣,៥២១ | ១,៣៨១ |
| ១៨ | ក្រចេះ | ៧ | ២៧៨ | ១៤៩ | | | |
| ១៩ | កំពង់ចាម | ២ | ៤៣០ | ២៣៦ | | | |
| ២០ | ត្បូងឃ្មុំ | ១ | ២១៨ | ១៤២ | ២៣ | ១,២៤៥ | ៧០៩ |
| សរុប | | ២,៧០៩ | ៣១៣,២២៥ | ១៥៤,៥២០ | ៦,៩៤៤ | ២៧៧,០៨០ | ១៤៣,៧១៧ |
| សរុបរួម (ខ១)+(ខ២) | | ៩៦៥៣ | | ៥៩០,៣០៥ | | ២៩៨,២៣៧ | |

*(ដោយឡែករាជធានី-ខេត្តដែលមិនមានរបាយការណ៍ស្តី ពីសកម្មភាពផ្សព្វផ្សាយអប់រំអំពីអំពើជួញដូរមនុស្ស និងបញ្ហាពាក់ព័ន្ធ មានចំនួន០៤ គឺ រាជធានីភ្នំពេញ, ប៉ៃលិន, ស្ទឹងត្រែង, មណ្ឌលគិរី, និងខេត្តបន្ទាយមានជ័យ។ )*

២.ខ.១.២. ការអនុវត្តវិធានការបង្ការ ទប់ស្កាត់

តាមបណ្តាច្រករបៀង ដែលជាទីតាំងឈរជើងរបស់កងកម្លាំងនគរបាលវរៈការពារព្រំដែនគោកលេខ ៨០៧ និង៩១១នៅខេត្តបន្ទាយមានជ័យ បានធ្វើការទប់ស្កាត់ និងអប់រំប្រជាពលរដ្ឋដែលព្យាយាមឆ្លងកាត់ព្រំដែនទៅប្រទេសថៃដោយខុសច្បាប់។ ដូចគ្នាដែរ នគរបាលប៉ុស្តិ៍អូរបីជាន់ នៃអធិការដ្ឋាននគរបាលស្រុកថ្មពួក និងស្រុកអូរជ្រៅ បានសហការជាមួយការិយាល័យប្រឆាំងការជួញដូរមនុស្ស និងវរៈការពារព្រំដែន ៨១៥ និង៩១១ ចុះទប់ស្កាត់ និងអប់រំពលករបម្រុងធ្វើចំណាកស្រុក ទៅរកការងារធ្វើនៅប្រទេសថៃដោយមិនមានច្បាប់ត្រឹមត្រូវ ឬតាមរយៈមេខ្យល់ ។

- ខេត្តបន្ទាយមានជ័យ៖ កងកម្លាំងនគរបាលវរៈ ការពារព្រំដែនគោកលេខ៨០៧ ,៨១៥ និង៩១១ ដោយមានការសហការជាមួយកម្លាំងប៉ុស្តិ៍អូរបីជាន់ បានធ្វើការទប់ស្កាត់ពលរដ្ឋខ្មែរ បម្រុងចំណាកស្រុក ដោយខុសច្បាប់ទៅរកការងារធ្វើនៅប្រទេសថៃចំនួន០៤លើក មនុស្សសរុបចំនួន១៥២នាក់ ស្រី៤២នាក់ ។

ពាក់ព័ន្ធនឹងការបង្ការទប់ស្កាត់ការជួញដូរមនុស្ស ក្នុងគោលដៅបម្រើសេវាកម្មផ្លូវភេទ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៦នេះ **លេខាធិការដ្ឋាន គ.ខ.ប. ខេត្ត** ,នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានសហការជាមួយស្ថាប័នពាក់ព័ន្ធដើម្បីធ្វើសកម្មភាពបង្ការទប់ស្កាត់តាមបណ្តាគោលដៅ សរុបបានចំនួន៥០៦គោលដៅ បើប្រៀបធៀបត្រីមាសទី៣ ឆ្នាំ២០១៥ មានតែចំនួន៤២គោលដៅ មានការកើនឡើងចំនួន៤៦៤គោលដៅ ស្មើនឹង១,១០៤.៧៦% មានមនុស្សសរុបចំនួន១,៧៨៦ បើប្រៀបធៀបត្រីមាសទី៣ ឆ្នាំ២០១៥ មានមនុស្ស១៥២២នាក់ មានការថយចុះចំនួន២៦៤នាក់ ស្មើនឹង១៧.៣៤% ស្រីសរុបចំនួន ៩០៥នាក់ និងទទួលបានលទ្ធផលដូចខាងក្រោម៖

- លេខាធិការដ្ឋាន គ.ខ.ប. ខេត្ត សហការជាមួយស្នងការដ្ឋាននគរបាលខេត្ត៖ ព្រះសីហនុ ,កែប ,កំពង់ស្ពឺ ឧត្តរមានជ័យ , និងខេត្តស្ទឹងត្រែង បានត្រួតពិនិត្យតាមដាននិងមានវិធានការទប់ស្កាត់បទល្មើសធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ និងការជួញដូរមនុស្សតាម សណ្ឋាគារ ផ្ទះសំណាក់ ខារ៉ាអូខេ, ផ្ទះជួលកោសជប់, ផ្ទះលក់កាហ្វេវីដេអូ និងជួលវីស៊ីឌី និងកន្លែងសេវាកម្សាន្ត នានា ដល់ម្ចាស់ក្រុមហ៊ុន បានចំនួន២០៨ គោលដៅមានមនុស្ស៩០១នាក់ស្រីចំនួន ២៣១នាក់ ។
- ក្រុមការងារអនុវត្តន៍ច្បាប់ ស្នងការដ្ឋាននគរបាលខេត្ត៖ កោះកុង, សៀមរាប, តាកែវ, កំពង់ឆ្នាំង ពោធិ៍សាត់, ក្រចេះ មណ្ឌលគិរី និងខេត្តព្រះវិហារ បានតាមដានគោលដៅសង្ស័យ និងចុះអប់រំតាមទីតាំងអាជីវកម្ម និងផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទដល់ម្ចាស់អាជីវកម្មទាំង២៩៨គោលដៅ ដល់មនុស្សចំនួន៨៨៥នាក់ (ស្រី៦៧៤នាក់) ។

២.ខ.១.៣.ការងារបង្ការទប់ស្កាត់តាមវិធានការជំនាញ

- ស្នងការដ្ឋាននគរបាលខេត្ត៖ ស្វាយរៀង, ព្រៃវែង, មណ្ឌលគិរី និងខេត្តតាកែវ បានល្បាតឃ្លាំមើលគោលដៅសង្ស័យមានមុខសញ្ញាអាជីវកម្មផ្លូវភេទចំនួន៣២លើក ។
- ធ្វើបច្ចុប្បន្នភាពទិន្នន័យគោលដៅសង្ស័យប្រព្រឹត្តបទល្មើសជួញដូរមនុស្ស និងអាជីវកម្មផ្លូវភេទទាំង ២៥រាជធានី-ខេត្ត ចំនួន៧១គោលដៅ ក្នុងនោះអំពើជួញដូរមនុស្សមាន០៥គោលដៅ និងអំពើធ្វើអាជីវកម្មផ្លូវភេទមានចំនួន៦៦គោលដៅ ។

២.ខ.១.៤. បង្ការទប់ស្កាត់តាមរយៈការរៀបអាពាហ៍ពិពាហ៍ខ្មែរ និងជនបរទេស

ការរួមគ្នាអនុវត្តអនុក្រឹត្យលេខ ១៨៣ អនក្រ.បក "ស្តីពីបែបបទ និងនីតិវិធីរវាងពលរដ្ឋខ្មែរ និងជនបរទេស" ដោយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងក្រសួងមហាផ្ទៃ គឺដើម្បីបង្ការទប់ស្កាត់អំពើរត់ពន្ធមនុស្ស និងអំពើជួញដូរមនុស្សតាមរូបភាពអាពាហ៍ពិពាហ៍តាំងពីឆ្នាំ២០០៩។ដោយឡែក ក្នុងត្រីមាសទី៣ ឆ្នាំ២០១៦ ការដាក់ពាក្យស្នើសុំរៀបអាពាហ៍ពិពាហ៍ ដែលត្រូវបានទទួលការអនុញ្ញាតឲ្យជនបរទេសចុះបញ្ជីអាពាហ៍ពិពាហ៍តាមការស្នើសុំតាមច្បាប់កំណត់ មានចំនួន៥០៤គូ។

បានធ្វើការសម្ភាសតាមដានស្ថានភាពទំនាក់ទំនង រវាងគូស្វាមី ភរិយា ដែលសង្ស័យថាមានបញ្ហានៅក្រៅប្រទេស តាមទូរស័ព្ទបានចំនួន៩០លើក។

## ២.ខ.២-ការគ្រប់គ្រងលំហូរពលករទេសន្តរប្រវេសន៍

### ២.ខ.២.១. ការគ្រប់គ្រងស្ថិតិចំណាកស្រុករបស់ពលរដ្ឋខ្មែរតាមខែនីមួយៗ

យោងតាមស្ថិតិរបស់អគ្គស្នងការដ្ឋាននគរបាលជាតិ ដែលមាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន និងស្នងការដ្ឋាននគរបាលរាជធានី-ខេត្ត បានស្រង់ទិន្នន័យអំពីពលរដ្ឋចំណាកស្រុក ក្នុងមូលដ្ឋានទូទាំងប្រទេស បានពិនិត្យឃើញថា ពលរដ្ឋចំណាកស្រុកទៅក្រៅប្រទេសនៅតែបន្តកើតមានឡើង ជាក់ស្តែងក្នុងត្រីមាសទី៣ ឆ្នាំ២០១៦នេះ តួលេខដូចតារាងខាងក្រោម៖

*តារាងតាមដានបច្ចុប្បន្នភាពទេសន្តរប្រវេសន៍របស់ពលរដ្ឋខ្មែរ ក្នុងត្រីមាសទី៣ ឆ្នាំ២០១៦(ក្នុងនិងក្រៅប្រទេស)*

| ប្រចាំខែ | សរុបរួម | | | | ស្របច្បាប់ | | | | មិនស្របច្បាប់ | | | |
|---|---|---|---|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | | សរុប | ស្រី | អនីតិជន | |
| | | | ប | ស | | | ប | ស | | | ប | ស |
| កក្កដា | ៣០១,៨០៦ | ១៣៧,៥០០ | ៥,៧៥១ | ២,២២៥ | ១៦៥,៥៤០ | ៨១,៦៦៩ | ៦៦៥ | ២៧៣ | ១៣៦,២៦៦ | ៥៥,៨៣១ | ៥,០៨៦ | ១,៩៥២ |
| សីហា | ៣០២,២៩៥ | ១៣៦,៧៦២ | ៥,៨១៣ | ២,២៤៧ | ១៦៦,៩០២ | ៨១,៦៤៩ | ៦៦៧ | ២៧៥ | ១៣៥,៣៩៣ | ៥៥,១១៣ | ៥,១៤៦ | ១,៩៧២ |
| កញ្ញា | ៣០៩,០៥៦ | ១៤១,៦២១ | ៥,៧៣៥ | ២,២៣០ | ១៧០,៩៨០ | ៨៤,៨១៧ | ៦៤៣ | ២៤១ | ១៣៨,០៧៦ | ៥៦,៨០៤ | ៥,០៩១ | ១,៩៨៩ |

### ២.ខ.២.២. ការគ្រប់គ្រងទ្នាក់ងារជ្រើសរើសឯកជន

ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ បានបង្កើនកិច្ចខិតខំប្រឹងប្រែង ក្នុងការគ្រប់គ្រងទីភ្នាក់ងារជ្រើសរើសពលករនៅក្នុងប្រទេសកម្ពុជា ដែលត្រូវចុះឈ្មោះ និងទទួលបានអាជ្ញាប័ណ្ណពីក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ស្របតាមច្បាប់ការងារនៃព្រះរាជាណាចក្រកម្ពុជា ។ លើសពីនេះទៅទៀត ទីភ្នាក់ងារជ្រើសរើសពលករឯកជន ត្រូវបានតម្រូវឲ្យមានថវិកាតម្កល់ទុក (មូលប័ត្រ) ដែលនឹងត្រូវប្រើប្រាស់សម្រាប់ការទូទាត់សំណង និងដោះស្រាយភាពវង្គោះរបស់ពលករចំណាកស្រុកដែលខ្លួនបានបញ្ជូន ។

ស្ថិតិបានបង្ហាញថាក្នុងត្រីមាសទី៣ ឆ្នាំ២០១៦ ពលករទៅធ្វើការដោយស្របច្បាប់នៅក្រៅប្រទេស(មិនមានរបាយការណ៍)

### ២.ខ. ៣.២-ការសិក្សាស្ថានភាពលំហូរជនទេសន្តរប្រវេសន៍ (តាមច្រកអន្តរជាតិ ប៉ោយប៉ែត ខេត្តបន្ទាយមានជ័យ)

តាមរបាយការណ៍ពីគណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ខេត្តបន្ទាយមានជ័យ ក្នុងត្រីមាសទី៣នេះ ក្រុមការងារទទួលជនទេសន្តរប្រវេសន៍បានឲ្យដឹងថា ថៃបានបញ្ជូនពលករត្រឡប់មកប្រទេសកម្ពុជាវិញ ក្រោមរូបភាព «និរទេស» តាមច្រកទ្វារអន្តរជាតិ ចំនួន១៧៩ជើង/រថយន្ត មានពលករខ្មែរចំនួន៧,៥៤៨នាក់ ក្នុងនោះស្រី ២,៥៤៧នាក់ កុមារ ៧០០នាក់ (កុមារី ៣០១នាក់)។ បើប្រៀបធៀបនឹងត្រីមាសទី៣ ឆ្នាំ២០១៥

មានចំនួន១៧,៥២៣ មានការថយចុះចំនួន៩,៩៧៥នាក់ គឺស្មើនឹង៥៦.៩២% ។ តាមរយៈការសម្ភាសខ្លី បានរកឃើញថា៖

- បានចេញតាមច្រកអន្តរជាតិ ៨,៧២០នាក់ តាមច្រករបៀង ៧,១០៥ នាក់
- ចេញដោយខ្លួនឯង ៥,៩១៧ នាក់ តាមគេនាំ ៦,៦០៧ នាក់
- *បានជាប់ពន្ធនាគារ លើសពី ១ខែ មាន ៨៥៤នាក់ ។*

ក្រុមការងារបានសម្ភាសពលករចំនួន៧៧៥នាក់ (ស្រី២៩២នាក់) មិនបានរកឃើញអត្តសញ្ញាណជនសង្ស័យជួញដូរមនុស្សទេ ។

បានសម្ភាសកុមារ១៥៦នាក់ (កុមារី ៦៤នាក់) ពិនិត្យឃើញថា៖

- កុមារ ៩៣ នាក់ ទៅតាមឪពុក ម្តាយ ធ្វើការនៅការដ្ឋានសំណង់
- កុមារ ៦៣នាក់ ទៅតាមបងប្អូន ទៅធ្វើការដកជំឡូង និងធ្វើការនៅការដ្ឋានសំណង់។

កុមារទាំងនោះបានឲ្យដឹងថា គេបានទទួលការឃោសនា អូសទាញពីមេខ្យល់តាមទូរស័ព្ទដែល មិនចាំលេខ មិនស្គាល់អត្តសញ្ញាណ។

នៅត្រីមាសទី៣ ឆ្នាំ២០១៦នេះ ពលរដ្ឋក្នុងខេត្តបន្ទាយមានជ័យ ធ្វើចំណាកស្រុកចំនួន៤,៨៨៤នាក់ (ស្រី២,១៨៤នាក់, កុមារ១០១នាក់) ក្នុងនោះ៖

- ចេញដោយស្របច្បាប់ ចំនួន ៦៩៥នាក់ (ស្រី៣២៥នាក់)
- ចេញដោយមិនស្របច្បាប់ ចំនួន ៤,១៩៤នាក់ (ស្រី១,៨៥៩នាក់ កុមារ៤៧០នាក់)

- ពលរដ្ឋក្នុងខេត្តបន្ទាយមានជ័យ ដែលត្រឡប់មកវិញ មានចំនួន២,៣៣៥នាក់ (ស្រីចំនួន៩៧៨នាក់ កុមារចំនួន៣១នាក់)។

## ២.ខ. ៣. ការងារ ការពារ ស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍

### ២.ខ.៣.១. ការងារការពារ និងស្តារនីតិសម្បទាជនរងគ្រោះ

គណៈកម្មាធិការខេត្តប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ខ.ប.ជ) បានសហការជាមួយអង្គការដៃគូចុះជួយដល់ជនរងគ្រោះ និងជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស រំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចកម្លាំងពលកម្ម ដោយបានធ្វើការស្តារនីតិសម្បទាជនរងគ្រោះទៅតាមអង្គការនានា ដើម្បីទទួលការពិនិត្យសុខភាព, ផ្តល់ប្រឹក្សាសម្រាប់ជម្រើស ឬការដោះស្រាយផ្លូវច្បាប់, ផ្តល់ជំនួយសង្គ្រោះបន្ទាន់, ផ្តល់ការស្នាក់នៅ និងអាហារ, ផ្តល់វគ្គបណ្តុះបណ្តាលជំនាញវិជ្ជាជីវៈ និងបំណិនជីវិត ទើបប្រគល់ឲ្យគ្រួសារវិញ សរុបបានចំនួន៣៥២នាក់ (ស្ត្រីមានចំនួន១៧១នាក់ កុមារាចំនួន៤០នាក់ និងកុមារីចំនួន៣២នាក់)ដូចរាយលម្អិតខាងក្រោម ៖

+ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា៖

- បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន២៩នាក់ ដើម្បីធ្វើការស្រាវជ្រាវរកគ្រួសារមុនពេលធ្វើមាតុភូមិនិវត្តន៍មកប្រទេសកំណើតវិញ ក្នុងនោះមាន(ប្រុស០២នាក់,ស្រីចំនួន២២,កុមារា០៣នាក់ និងកុមារី០២នាក់ )៖
  - មជ្ឈមណ្ឌលសំចតប៉ោយប៉ែតចំនួន០៧នាក់(ប្រុស០១នាក់,ស្រី០១នាក់,កុមារា០៣នាក់ និងកុមារី០២នាក់)
  - មន្ទីរសង្គមកិច្ច រាជធានី/ខេត្ត និងអង្គការដៃគូ មានចំនួន២២នាក់ ស្រីចំនួន២១នាក់ ។

- បានទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៧នាក់ ឲ្យស្នាក់នៅមណ្ឌលស្តារនីតិសម្បទារយៈពេលខ្លី (ប្រុស០១នាក់,ស្រី០១នាក់,កុមារា០៣នាក់ និងកុមារី០២នាក់) ។
- មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានី/ខេត្ត និងអង្គការពាក់ព័ន្ធបានទទួលជនរងគ្រោះ សរុបចំនួន៤១នាក់(ស្រីចំនួន២៥នាក់ កុមារា០៥ កុមារីចំនួន១១នាក់) ក្នុងនោះមកពីៈ
  - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ បានទទួលជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម សរុបចំនួន២៧នាក់ស្រីចំនួន២២នាក់ កុមារីចំនួន០៥នាក់ ។
  - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង បានទទួលកុមាររងគ្រោះដោយអំពើជួញដូរកម្លាំងពលកម្ម ដែលបានធ្វើមាតុភូមិនិវត្តន៍ពីប្រទេសវៀតណាម ចំនួន១១នាក់( កុមារា០៥ ,កុមារី០៦នាក់ )។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា រាជធានីភ្នំពេញ បានទទួលជនអនាថាមិនស្ម័គ្រចិត្តសរុបចំនួន១៩៤នាក់ (ស្រីចំនួន៦៨នាក់) នៅ(ខណ្ឌដូនពេញចំនួន៨៩នាក់ ,ខណ្ឌ៧មករា១៦នាក់ ខណ្ឌទួលគោក១០នាក់ ,ខណ្ឌមានជ័យ១៩នាក់ ,ខណ្ឌចម្ការមន០២នាក់ ,ខណ្ឌដង្កោ០៣នាក់ ,ខណ្ឌជ្រោយចង្វារ០២នាក់ ,ព្រែកព្នៅ១៧នាក់ ,ខណ្ឌសែនសុខ០២នាក់ ,ខណ្ឌច្បារអំពៅ០១នាក់ ,ក្រុមការងារមន្ទីរចុះជួយសង្គ្រោះ០៥នាក់ វិទ្យុABC ០១នាក់ ទទួលសមាហរណកម្មពីមណ្ឌលឱកាសខ្ញុំ១៨នាក់ ។ បានធ្វើការ ពិគ្រោះយោបល់ និងបញ្ជូនជនរងគ្រោះទៅមណ្ឌលសំចតសង្គមកិច្ចរាជធានីភ្នំពេញទាំង១៩៤នាក់ ដើម្បីអប់រំណែនាំបណ្តុះបណ្តាល រយៈពេលខ្លី និងសមាហរណកម្មទៅសហគមន៍វិញ ។

-បានទទួលនារីរងគ្រោះដោយអំពើជួញដូរផ្លូវភេទចំនួន១០នាក់ ពីការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលក្រុង និងបានពិគ្រោះយោបល់ បានបញ្ជូននារីរងគ្រោះចំនួន០៧នាក់ទៅអង្គការបណ្តាញស្ត្រីរួមគ្នា(WNU) និងទៅអង្គការមេត្រីអន្តរជាតិអាស៊ីចំនួន០៣នាក់ ។

-បានទទួលនារីរងគ្រោះដោយអំពើជួញដូរផ្លូវភេទចំនួន០៩នាក់ ពីខណ្ឌដូនពេញចំនួន០៧នាក់ ខណ្ឌចម្ការមនចំនួន០២នាក់ និងបានពិគ្រោះយោបល់បញ្ជូននារីរងគ្រោះទាំង០៩នាក់ទៅអង្គការបណ្តាញស្ត្រីរួមគ្នា(WNU)។

+ក្រុមការងាររបស់លេខាធិការដ្ឋាន បានសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជននិងយុវនីតិសម្បទាខេត្ត កំពង់ធំៈ

- បានចុះជួយជនរងគ្រោះដោយអំពើជួញដូរផ្លូវភេទ ដើម្បីទទួលសេវាថែទាំសុខភាព មានចំនួន០៤នាក់(ស្រី)(អនីតិជនចំនួន០១នាក់ និងនីតិជន០៣នាក់) ដែលយកបានពីទីតាំងខារ៉ាអូខេ ស្ថិតនៅក្នុងស្រុកស្ទោងព្រមទាំងបានធ្វើការអប់រំណែនាំ និងឲ្យវិលត្រឡប់ទៅស្រុកកំណើតវិញ។
- បានទទួលពលការិនីចំនួន០១នាក់ធ្វើការនៅក្រៅប្រទេស រស់នៅក្នុងភូមិបាល័ង្គខាងលិច ឃុំលេខ១ ទីរួមខេត្តកំពង់ធំ ដែលមកតាមរយៈក្រសួងការបរទេសបញ្ជូនមកក្រសួងសង្គមកិច្ចរាជធានីភ្នំពេញ និងត្រូវបានអង្គការរតនៈយកមកបណ្តុះបណ្តាលវិជ្ជាជីវៈ ដើម្បីឲ្យគាត់មានមុខរបរ ។

- បានសហការជាមួយមណ្ឌលអង្គការកម្ពុជាដើម្បីការពារកុមារ បានទទួលពលករនីចំនួន០២នាក់រងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបានត្រឡប់មកពីប្រទេស ម៉ាឡេស៊ី និងក្រោយពីបានអប់រំ ណែនាំ និងបញ្ជូនឲ្យទៅរស់នៅជាមួយឪពុកម្តាយវិញ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្តសៀមរាប

- បានបញ្ជូនបុគ្គលិក០២នាក់ ទៅសម្ភាសដើម្បីកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន០៧នាក់(ក្នុងនោះមានប្រុស០១នាក់ ស្រី០១នាក់កុមារា០៣នាក់ និងកុមារី០២នាក់) ០៦នាក់បានកំណត់អត្តសញ្ញាណរួចរាល់ និងបានធ្វើសមាហរណកម្មទៅសហគមន៍វិញ និងចំនួន០១នាក់បានបញ្ជូនទៅស្នាក់នៅអង្គការ Hagar ។
- បានសហការជាមួយការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការដ្ឋាននគរបាលខេត្ត បានទទួលពលករចំណាកស្រុកត្រឡប់មកពីប្រទេសម៉ាឡេស៊ី ចំនួន០៣នាក់ (ស្រី) និងបានធ្វើការអប់រំណែនាំមុននឹងបញ្ជូនទៅតាមមូលដ្ឋាន ស្រុកកំណើតវិញ ក្នុងនោះ(ខេត្តកំពង់ធំ ចំនួន០១នាក់ ខេត្តកំពង់ចាមចំនួន០២នាក់)។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តក្រចេះ

-បានចុះប៉ាន់ប្រមាណគ្រួសាររងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន០២ មកពីអង្គការមេត្រីអន្តរជាតិដើម្បីអាស៊ី ចំនួន០១នាក់ និងស្រុកព្រែកប្រសព្វចំនួន០១នាក់ ។

-បានសហការជាមួយអង្គការមជ្ឈមណ្ឌលកម្ពុជា (CCPCR) ដើម្បីការពារសិទ្ធិកុមាររងគ្រោះ និងបានធ្វើសមាហរណកម្មជនរងគ្រោះមកពីប្រទេសម៉ាឡេស៊ីចំនួន២១នាក់ និងបានធ្វើការអប់រំណែនាំមុននឹងបញ្ជូនទៅសហគមន៍វិញ ក្នុងនោះ(ស្រុកឆ្លូងចំនួន១៨នាក់ ស្រី០៣នាក់ ស្រុកព្រែកប្រសព្វចំនួន០៣នាក់ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង បានទទួលប្រជាពលរដ្ឋខ្មែរឆ្លងដែនខុសច្បាប់ទៅប្រកបរបរលក់ឆ្នោតនៅប្រទេសវៀតណាម ចំនួន៤គ្រួសារ មានចំនួនមនុស្ស០៩នាក់ ស្រីចំនួន០៧នាក់ ព្រមទាំងបានធ្វើកិច្ចសន្យា និងអប់រំណែនាំមុននឹងបញ្ជូនទៅតាមមូលដ្ឋាន ស្រុកកំណើតវិញ ។

+ក្រុមការងាររបស់លេខាធិការដ្ឋាន បានសហការជាមួយមន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកំពង់ចាមៈ

-បានជួយសង្គ្រោះនារីរងគ្រោះចំនួន០១នាក់ដោយចាញ់បោកមេខ្យល់ឲ្យទៅរៀនបន្តនៅប្រទេសចិន និងបានបញ្ជូនទៅអង្គការរតនៈអិនធឺណេសិនណលនៅភ្នំពេញ ដើម្បីទទួលសេវាអប់រំបន្ត ។

-បានជួយសង្គ្រោះនារីរងគ្រោះដោយអំពើជួញដូរមនុស្ស និងការកេងប្រវ័ញ្ចផ្លូវភេទ ចំនួន០៤នាក់ មកពី(ខេត្តកំពង់ចាមចំនួន០២នាក់ ,ខេត្តត្បូងឃ្មុំចំនួន០២នាក់ ) និងបានបញ្ជូនទៅស្តារកាយ សម្បទា អង្គការសង្គ្រោះជោគ វាសនាកម្ពុជា ។

-បានសហការជាមួយអង្គការភ្នំស្រីដើម្បីអភិវឌ្ឍន៍ ចុះដល់មូលដ្ឋានភូមិត្រពាំងកក់ ឃុំអូរស្វាយ ស្រុកកំពង់សៀម បានជួបពិភាក្សាជាមួយក្រុមប្រឹក្សា ភូមិ ឃុំ ជួយដោះស្រាយជូនពលករចំនួន១២នាក់

ក្នុងចំណោមពលករ១៥នាក់ ដែលក្រុមហ៊ុន JOB ASIA CAMBODIA LIMITED ដែលបានបង់ប្រាក់ចំនួន៣០០ដុល្លារយល់ព្រមផ្តល់លិខិតឆ្លងដែនជូនពលករវិញ ។

-សហការជាមួយអង្គការ ជួយ និងបញ្ជូននារីរងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៤នាក់ និងការកេងប្រវ័ញ្ចផ្លូវភេទ ក្នុងនោះមកពីខេត្តកំពង់ចាមចំនួន០២នាក់ ខេត្តត្បូងឃ្មុំចំនួន០២នាក់ ទៅអង្គការសង្គ្រោះដោគវាសនាកម្ពុជា ។

-សហការជាមួយអង្គការ ជួយ និងបញ្ជូននារីរងគ្រោះដោយអំពើជួញដូរមនុស្ស ចំនួន០១នាក់ ដែលចាញ់បោកមេខ្យល់ទៅរៀនបន្តនៅប្រទេសចិន ទៅឲ្យអង្គការរតនៈ អ៊ីនធឺណេសិនណលនៅភ្នំពេញ ដើម្បីទទួលសេវាបន្ត ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ បានចុះជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឲ្យស្នាក់នៅរយៈពេលខ្លី នៅមណ្ឌលស្តារនីតិសម្បទា ចំនួន២៨នាក់(ក្នុងនោះមានប្រុស០១នាក់ ស្រី០៥ នាក់ កុមារា១៦នាក់ និងកុមារី០៥នាក់) ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្ទឹងត្រែង បានសហការជាមួយអង្គការសម្ព័ន្ធចាប់ដៃ បានចុះទៅសម្ភាសជនរងគ្រោះ ដោយអំពើជួញដូរមនុស្សចំនួន១២នាក់ ស្រីចំនួន០៨នាក់ក្នុងនោះអនីតិជនចំនួន០៥ នាក់ ស្រីចំនួន០៤ នាក់ នៅភូមិអូឬស្សីកណ្តាល ស្រុកសៀមបូក ។

### ២.ខ. ៣.២-ការងារទេសន្តរប្រវេសន៍

❖ **ការទទួលពលរដ្ឋខ្មែរពីអាជ្ញាធរបរទេស៖**

ក្នុងត្រីមាសទី៣នេះ ចំនួនជនដែលបានធ្វើមាតុភូមិនិវត្តន៍ និងបានបញ្ជូនត្រឡប់ដោយអាជ្ញាធរមានសមត្ថកិច្ចបរទេស មិនត្រូវបានរកឃើញថា ជាជនរងគ្រោះដោយអំពើជួញដូរទាំងអស់ទេ តែជាជនសង្ស័យថារងគ្រោះក្នុងអំឡុងពេលធ្វើទេសន្តរប្រវេសន៍ ដោយអំពើហិង្សា ការកេងប្រវ័ញ្ច ការរំលោភលើទំនុកចិត្តជាដើម។ ជនទាំងនោះមានសិទ្ធិដាក់បណ្តឹងទាមទារយុត្តិធម៌បាន តែបទល្មើសជាច្រើនករណី មិនកើតនៅក្នុងព្រះរាជាណាចក្រកម្ពុជាទេ។

ជនដែលត្រូវបានបញ្ជូនត្រឡប់តាមអាជ្ញាធរបរទេសសរុបចំនួន១៣,៧៩៣នាក់ (ស្រី៤,៦៩១នាក់) ក្នុងនោះមកតាម ៖

- ✓ ផ្លូវអាកាស ចំនួន៦៨នាក់(ស្រី២៥នាក់)
- ✓ ផ្លូវគោក ចំនួន១៣,៧២៥នាក់(ស្រី៤,៦៦៦នាក់)កុមារចំនួន១,៣៥១នាក់(កុមារីចំនួន៤៩១នាក់)

តារាងជនដែលត្រូវបានបញ្ជូនត្រឡប់ (តាមផ្លូវគោក និងផ្លូវអាកាស)

| បញ្ជូនត្រឡប់ពីប្រទេស | ផ្លូវគោក | | | | ផ្លូវអាកាស | | | |
|---|---|---|---|---|---|---|---|---|
| | សរុប | ស្រី | កុមារសរុប | កុមារី | សរុប | ស្រី | កុមារសរុប | កុមារី |
| ម៉ាឡេស៊ី | | | | | ៥៤ | ១១ | | |
| ចិន | | | | | ១៤ | ១៤ | | |
| ថៃ | ១៣,៦៨១ | ៤,៦៤៣ | ១,៣២៩ | ៤៧៩ | | | | |
| វៀតណាម | ៤៤ | ២៣ | ២២ | ១២ | | | | |
| សរុប | ១៣,៧២៥ | ៤,៦៦៦ | ១,៣៥១ | ៤៩១ | ៦៨ | ២៥ | | |

- មានប្រជាពលរដ្ឋខ្មែរចំនួន៧៧២នាក់ ត្រូវអាជ្ញាធរថៃឃាត់ខ្លួនលើសពីរយៈពេល១ខែ មុនបញ្ជូនមកកម្ពុជា។ ក្រោយធ្វើការសម្ភាសរួចពលរដ្ឋខ្មែរទាំងអស់ត្រូវបានអប់រំណែនាំឲ្យត្រឡប់ទៅលំនៅដ្ឋានវិញ ។

❖ **ការការពារពលករទេសន្តរប្រវេសន៍ ពលកររងគ្រោះនៅក្រៅប្រទេស(នាយកដ្ឋាន)**

ជាមួយនឹងការប្តេជ្ញាចិត្តខ្ពស់ចំពោះការដោះស្រាយបញ្ហា និងជួយពលករដែលរងគ្រោះ មានលក្ខណៈជាប្រព័ន្ធ ក្នុងការកេងប្រវ័ញ្ចកម្លាំងពលកម្មក្នុងឧស្សាហកម្មនេសាទសមុទ្រ, បម្រើការតាមផ្ទះ, ការរៀបអាពាហ៍ពិពាហ៍ នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ដោយបានសហការជាមួយក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ និងទូតនានានៅប្រទេសគោលដៅ បានប្រមូលទិន្នន័យអំពីពលករទេសន្តរប្រវេសន៍នៅប្រទេសគោលដៅ និងរិះរកវិធានការដើម្បីការពារសុវត្ថិភាពពលករទេសន្តរប្រវេសន៍ ដែលបម្រើការងារតាមរយៈ៖

○ *បាតុភាពពលកររងគ្រោះ៖*

| បញ្ជូនពី | សរុប | នេសាទ | បម្រើតាមផ្ទះ | អាពាហ៍ពិពាហ៍ | មកវិញតាមរយៈ | |
|---|---|---|---|---|---|---|
| | | | | | ការបរទេស | IOM |
| ម៉ាឡេស៊ី | ៥៤ | | ៥៤ | | | ៥៤ |
| ចិន | ១៤ | | | ១៤ | | ១៤ |
| សរុប | ៦៨ | | ៥៤ | ១៤ | | ៦៨ |

❖ សំគាល់: ក្រុមហ៊ុន១៦នាក់ មេខ្យល់៤០នាក់ ខ្លួនឯង១២នាក់ ។

## ២.ខ.៤.ការងារអនុវត្តច្បាប់

ក្នុងត្រីមាសទី៣នេះ យើងទទួលបានលទ្ធផលបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ពីបណ្តាអង្គភាពចំនួន១៤ គឺស្នងការនគរបាលខេត្តៈ បន្ទាយមានជ័យ, កំពង់ចាម, កំពង់ឆ្នាំង,

កណ្តាល, កោះកុង, ក្រចេះ ,រាជធានីភ្នំពេញ, ព្រៃវែង, ពោធិ៍សាត់, រតនគិរី, សៀមរាប, ស្វាយរៀង នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន នៃអគ្គស្នងការដ្ឋាននគរបាលជាតិ ក្រសួងមហាផ្ទៃ និងកងរាជអាវុធហត្ថលើផ្ទៃប្រទេស។

### ២.ខ.៤.១.ការងារបង្ក្រាប និងសង្គ្រោះជនរងគ្រោះ៖

ក្នុងត្រីមាសទី៣ ឆ្នាំ២០១៦នេះ ក្រុមការងារអនុវត្តន៍ច្បាប់ដែលដឹកនាំដោយអគ្គស្នងការនៃអគ្គស្នងការដ្ឋាននគរបាលជាតិ រួមជាមួយទីភ្នាក់ងារអនុវត្តច្បាប់ដទៃទៀត បានខិតខំបំពេញភារកិច្ចយ៉ាងសកម្ម។ ក្នុងការបង្ក្រាប និងទប់ស្កាត់អំពើជួញដូរមនុស្ស។

ការផ្លាស់ប្តូរប្រែប្រួលយ៉ាងសំខាន់ខាងផ្នែកសមត្ថភាព ឥរិយាបថ និងការប្តេជ្ញាចិត្តរបស់មន្ត្រីអនុវត្តន៍ច្បាប់ នៅក្នុងនីតិវិធីស៊ើបអង្កេត ប្រមូលភស្តុតាង និងតាមប្រព័ន្ធតុលាការក្នុងរឿងក្តីជួញដូរមនុស្ស បានធ្វើឲ្យកើនឡើងនូវប្រសិទ្ធភាព លើមូលដ្ឋាននៃការស៊ើបអង្កេតពីករណីមួយទៅករណីមួយ ដោយផ្តោតទៅលើទំហំករណី និងបណ្តាញសមាគមនៃជនទុច្ចរិត ជួញដូរមនុស្ស។

ត្រីមាសទី៣ ឆ្នាំ២០១៦នេះ ដោយមានការសហការជាមួយព្រះរាជអាជ្ញាតាមបណ្តារាជធានី/ខេត្ត សកម្មភាពបង្រ្កាបអនុវត្តបានចំនួន៣១ករណី (លើ២០ករណី បើប្រៀបធៀបត្រីមាសទី៣ឆ្នាំ២០១៥ ថយចុះចំនួន៦ករណី)។ ឃាត់ខ្លួនជនសង្ស័យបានចំនួន៤២នាក់ ស្រី២៣នាក់ (អនីតិជន០២នាក់)ត្រូវបានចាប់ខ្លួន ក្នុងនេះចំនួនជនសង្ស័យដែលជាជនបរទេសចំនួន០៣នាក់ មាន០៣សញ្ជាតិៈ ថៃ ហូឡង់ និងប៉ាគីស្ថាន។

ដោយឡែកជនរងគ្រោះ ដែលសង្រ្គោះបានក្នុងករណីជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ សរុបមានចំនួន១០០នាក់ ក្នុងនោះអាយុក្រោម១៥ឆ្នាំចំនួន១២នាក់ អាយុពី១៥-ក្រោម១៨ឆ្នាំចំនួន១៤នាក់ អាយុ១៨ឡើងចំនួន៧៤នាក់ បានបញ្ជូនទៅមន្ទីរសង្គមកិច្ចចំនួន៥៤នាក់ គ្រួសារចំនួន៤៣នាក់ និងអង្គការដៃគូចំនួន០៣នាក់ ។

ដោយមានការដឹកនាំ និងកិច្ចសហការសម្របសម្រួលយ៉ាងជិតស្និទ្ធ រវាងអគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងការជួញដូរមនុស្ស (គ.ជ.ប.ដ) ជាមួយស្ថាប័នអនុវត្តន៍ច្បាប់ មានអគ្គស្នងការដ្ឋាននគរបាលជាតិ កងរាជអាវុធហត្ថ ក្រសួងមហាផ្ទៃ ក្រសួងយុត្តិធម៌ ស្ថាប័នអាយ្យការ និងស្ថាប័នតុលាការ បានធ្វើការបង្រ្កាបអំពើជួញដូរមនុស្ស និងការផ្តន្ទាទោសជនល្មើស ទទួលបានលទ្ធផលល្អគួរជាទីពេញចិត្ត ទាំងបរិមាណ និងគុណភាព ដែលទទួលបានលទ្ធផលជារួមៈ

### ១. ករណីអំពើជួញដូរមនុស្សៈ

បង្រ្កាបបាន១៣ករណី/០៧ករណី(កើន០៦ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន២០នាក់ (ស្រី១៤នាក់) ជនបរទេសចំនួន០២នាក់ (សញ្ជាតិថៃ និងប៉ាគីស្ថាន) សង្រ្គោះជនរងគ្រោះបានចំនួន៣៦នាក់។ បទល្មើសពាក់ព័ន្ធៈ

-ការនាំយកចេញដោយមិនស្របច្បាប់ដោយមានគោលដៅ ០៥ ករណី ជនសង្ស័យ ០៧ នាក់
-ការនាំយកចេញដោយមិនស្របច្បាប់សម្រាប់នាំឆ្លងដែន ០៦ ករណី ជនសង្ស័យ ១១ នាក់ (សញ្ជាតិថៃ០១នាក់ និងប៉ាគីស្ថាន០១នាក់)
-អំពើលក់ដូរ-មនុស្សសម្រាប់នាំឆ្លងដែន ០២ ករណី ជនសង្ស័យ ០២ នាក់

*បញ្ជីជនរងគ្រោះដោយអំពើជួញដូរមនុស្សដែលសង្រ្គោះបានក្នុងពេលប្រតិបត្តិការបង្រ្កាបៈ*

| ចំនួនជនរងគ្រោះសរុប | អាយុក្រោម ១៥ឆ្នាំ | ពី១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ | អាយុ១៨ឆ្នាំ ឡើង | ការបញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|
| | | | | ទៅមន្ទីរស/ក | ទៅអង្គការ | ទៅគ្រួសារ |
| ៣៦ | ០១ | ០៨ | ២៧ | ០៦ | ០ | ៣០ |

### ២. អំពើជួញដូរផ្លូវភេទៈ

បង្រ្កាបបាន១៨ករណី/១៣ករណី (កើន០៥ករណី) ឃាត់ខ្លួនជនសង្ស័យចំនួន២២នាក់ ស្រី០៩នាក់ (អនីតិជន០២នាក់) ជនបរទេស០១នាក់ បទល្មើសពាក់ព័ន្ធៈ

-សញ្ចារកម្ម (មានអនីតិជន) ០២ ករណី ជនសង្ស័យ ០៣ នាក់
-ស្ថានភាពទម្ងន់ទោសនៃសញ្ចារកម្ម ០៤ ករណី ជនសង្ស័យ ០៦ នាក់
-សញ្ចារកម្ម (ទាក់ទងនឹងពេស្យាចារកុមារ) ០២ ករណី ជនសង្ស័យ ០២ នាក់
-រូបភាព និងសម្ភារៈអាសអាភាស ០១ ករណី ជនសង្ស័យ ០១ នាក់ (សញ្ជាតិហូឡង់)

-ការផ្ដល់ទីកន្លែងសម្រាប់ធ្វើពេស្យាចារ ០២ ករណី ជនសង្ស័យ ០៣ នាក់
-អំពើរួមភេទជាមួយអនីតិជនអាយុក្រោម១៥ឆ្នាំ ០៥ករណី ជនសង្ស័យ០៥នាក់
(ជនសង្ស័យជាអនីតិជន០១នាក់ សញ្ជាតិឥណ្ឌា០១នាក់)
-អំពើអាសអាភាសប្រឆាំងនឹងអនីតិជនអាយុក្រោម១៥ឆ្នាំ ០២ករណី ជនសង្ស័យ០២នាក់។
(ជនសង្ស័យជាអនីតិជន០១នាក់)

*បញ្ជីជនរងគ្រោះដោយអំពើធ្វើអាជីវកម្មផ្លូវភេទ ដែលសង្គ្រោះបានក្នុងពេលប្រតិបត្តិការបង្ក្រាប៖*

| ចំនួនជនរងគ្រោះសរុប | អាយុក្រោម ១៥ឆ្នាំ | ពី១៥ឆ្នាំ ដល់ក្រោម១៨ឆ្នាំ | អាយុ១៨ឆ្នាំឡើង | ការបញ្ជូនជនរងគ្រោះ | | |
|---|---|---|---|---|---|---|
| | | | | ទៅមន្ទីរស/ក | ទៅអង្គការ | ទៅគ្រួសារ |
| ៦៤ | ១១ | ០៦ | ៤៧ | ៤៨ | ០៣ | ១៣ |

សកម្មភាពបង្ក្រាបនៅតាមរាជធានី/ខេត្ត៖

នៅតាមបណ្ដារាជធានី/ខេត្ត បានយកចិត្តទុកដាក់ក្នុងការបង្ក្រាបករណីបទល្មើសជួញដូរមនុស្សយ៉ាងសកម្មផងដែរ។ តារាងស្ថិតិខាងក្រោមនេះបង្ហាញអំពីលទ្ធផលនៃការអនុវត្តរបស់រាជធានី/ខេត្ត នៅក្នុងការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ នៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៦៖

*<u>តារាងស្ថិតិលទ្ធផលបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទរាជធានី/ខេត្ត៖</u>*

| ល.រ | នាយកដ្ឋាន រាជធានី ខេត្ត | បង្ក្រាបរួម | ជនល្មើស | | | ជនរងគ្រោះ | | | |
|---|---|---|---|---|---|---|---|---|---|
| | | | រួម | ស្រី | បរទេស | រួម | -១៥ | ១៥-១៧ | ១៨+ |
| ១ | បន្ទាយមានជ័យ | ២ | ២ | ១ | | ៣ | | | ៣ |
| ២ | កំពង់ចាម | ២ | ២ | ២ | | ៧ | ១ | ២ | ៤ |
| ៣ | កំពង់ឆ្នាំង | ១ | ១ | | | ២ | ២ | | |
| ៤ | កណ្ដាល | ១ | ១ | | | ១ | ១ | | |
| ៥ | កោះកុង | | | | | | | | |
| ៦ | ក្រចេះ | ១ | ២ | ២ | | ១ | | | ១ |
| ៧ | ភ្នំពេញ | ១៣ | ១៧ | ៨ | ២ | ៥១ | ៥ | ៥ | ៤១ |
| ៨ | ព្រៃវែង | ២ | ៣ | ២ | | ២ | | ១ | ១ |
| ៩ | ពោធិ៍សាត់ | ១ | ១ | | | ១ | ១ | | |
| ១០ | រតនគិរី | ១ | ១ | ១ | | ១ | | | ១ |
| ១១ | សៀមរាប | ១ | ១ | | ១ | ១ | ១ | | |
| ១២ | ស្វាយរៀង | ១ | ១ | | | ១ | | ១ | |
| ១៣ | នាយកដ្ឋាន | ៤ | ៩ | ៧ | | ២៥ | | ៥ | ២០ |
| ១៤ | កងរាជអាវុធហត្ថ | ១ | ១ | | | ៤ | ១ | | ៣ |
| **សរុប** | | **៣១** | **៤២** | **២៣** | **៣** | **១០០** | **១២** | **១៤** | **៧៤** |

(ដោយឡែកខេត្តចំនួន១៣ទៀត ក្នុងត្រីមាសទី៣នេះ មិនមានរបាយការណ៍ស្តីពីសកម្មភាពបង្ក្រាបបទល្មើសជួញដូរមនុស្សទេ ដូចជាខេត្តៈ បាត់ដំបង, កំពង់ស្ពឺ, កំពង់ធំ, កំពត, មណ្ឌលគិរី, ព្រះវិហារ, ព្រះសីហនុ ស្ទឹងត្រែង, តាកែវ, ឧត្តរមានជ័យ, កែប, ប៉ៃលិន និងខេត្តត្បូងឃ្មុំ)។

### ២.១.៥. កិច្ចការយុត្តិធម៌ (មិនទាន់មានរបាយការណ៍ត្រីមាសទី៣)

ទិន្នន័យទទួលបានពីក្រុមការងារកិច្ចការយុត្តិធម៌ ដឹកនាំដោយក្រសួងយុត្តិធម៌ ដែលបានដកស្រង់លទ្ធផលពីសាលាដំបូងរាជធានី-ខេត្ត ការងារផ្តន្ទាទោស នៅក្នុងត្រីមាសទី៣ ឆ្នាំ២០១៦ តុលាការរាជធានី-ខេត្ត បានធ្វើចំណាត់ការលើសំណុំរឿងបទល្មើសក្រោមច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ និងមាត្រាពាក់ព័ន្ធនៃក្រមព្រហ្មទណ្ឌ។ ជាលទ្ធផលតាមដំណាក់កាលនៃនីតិវិធីតុលាការ មិនទាន់បានបូកសរុបបញ្ចប់លទ្ធផលនៅឡើយ ។

### ២.១. ៦.ការងារសហប្រតិបត្តិការអន្តរជាតិ

ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ បានចូលរួមកិច្ចប្រជុំ និងបំពេញកិច្ចសហប្រតិបត្តិការលើការងារពាក់ព័ន្ធទៅនឹងអំពើជួញដូរមនុស្ស នៃប្រទេសក្នុងតំបន់សរុបមានចំនួន១០លើក ក្នុងនោះមានៈ អនុប្រធានអចិន្ត្រៃយ៍ និងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការជាតិ គ.ជ.ប.ជ ចំនួន០១លើក, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន០១លើក នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន០១លើក, និងលេខាធិការដ្ឋានរាជធានី/ខេត្ត០៧លើក។

*តារាងកិច្ចសហប្រតិបត្តិការ*

| ក្រសួង ស្ថាប័ន | សកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | បានចាត់បញ្ជូន ប្រធានក្រុមជំនួយបច្ចេកទេសកិច្ចសហប្រតិបត្តិការអន្តរជាតិចូលរួមៈ<br>- បានដឹកនាំរៀបចំកិច្ចប្រជុំទ្វេភាគីចិន-កម្ពុជា ដែលគណៈប្រតិភូចិនដឹកនាំដោយលោក ឆេន ស៊ីគូ អគ្គនាយករង នៃអគ្គនាយកដ្ឋានស៊ើបអង្កេត របស់ក្រសួងសន្តិសុខសាធារណៈ ដើម្បីពិភាក្សាសម្រេចលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅសណ្ឋាគារសុខាល័យអង្គរ ខេត្តសៀមរាប ថ្ងៃទី២៤ ដល់២៦ ខែសីហា ឆ្នាំ២០១៦ ។ |
| ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា | - បានចូលរួមកិច្ចប្រជុំពិភាក្សា កែសម្រួលខ្លឹមសារឯកសារណែនាំ ស្តីពីនីតិវិធីប្រគល់ និងទទួលជនរងគ្រោះដោយ អំពើជួញដូរមនុស្ស រវាងព្រះរាជាណាចក្រកម្ពុជា និងសាធារណៈរដ្ឋសង្គមនិយមវៀតណាម ។ |
| នាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស និងការពារអនីតិជន | - នាយកដ្ឋានប្រឆាំងការជួញដូរមនុស្សនិងការពារអនីតិជន បានចាត់បញ្ជូននាយនគរបាលចំនួន០១រូប ចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការប្រយុទ្ធប្រឆាំងការឆ្លងដែនខុសច្បាប់ ដល់បណ្តាប្រទេសជាសមាជិកអាស៊ាន (នៅប្រទេសចិន) ។ |
| ខេត្តព្រះវិហារ | - ស្នងការដ្ឋាននគរបាលខេត្ត បានចូលរួមកិច្ចប្រជុំជាមួយប្រទេសថៃ និងប្រទេសឡាវបានចំនួន០៣លើក ស្តីពីកិច្ចសហប្រតិបត្តិការការការពារសន្តិសុខនៅតាមបណ្តោយព្រំដែន និងបញ្ហាពលករធ្វើចំណាកស្រុកដោយប្រថុយប្រថាន ដើម្បីស្វែងរកការងារធ្វើនៅក្រៅប្រទេស និងការពាក់ព័ន្ធអំពើជួញដូរមនុស្ស ការឆ្លងដែនខុសច្បាប់ ។ |
| ខេត្តស្វាយរៀង | - ស្នងការដ្ឋាននគរបាលខេត្ត បានសហការជាមួយអង្គការសន្តិសេនា ដឹកនាំប្រតិភូក្រុមការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សចំនួន១៥នាក់ ស្រីចំនួន០៧នាក់ ទៅខេត្តតៃនិញប្រទេសវៀតណាម ដើម្បីពិភាក្សាពីគ្រោះយោបល់ លើការងារសំខាន់ស្តីពីៈ |

| | |
|---|---|
| | - ការរៀបចំ និងបង្កើតការងារការពារ និងជួយកុមារឆ្លងដែន<br>- ពិភាក្សាលើភារកិច្ច និងការទទួលខុសត្រូវរបស់ក្រុមការងារនៃខេត្តនីមួយៗ<br>- ដំណើការនៃកិច្ចប្រជុំរបស់ក្រុមការងាររវាងខេត្តទាំង៣ ។<br>- ស្នងការដ្ឋាននគរបាលខេត្ត បានសហប្រតិបត្តិការជាមួយនគរបាលខេត្តឡុងអានប្រទេសវៀតណាមបាន ធ្វើការប្រជុំ ស្តីពីការបង្ក្រាបបទល្មើសអំពើជួញដូរមនុស្ស និងការពារសន្តិសុខសណ្តាប់ធ្នាប់ព្រំដែន រវៀង ប្រទេសកម្ពុជា និងប្រទេសវៀតណាមលើកទី១៣ មានអ្នកចូលរួមចំនួន៤៣នាក់ ស្រីចំនួន០២នាក់ ។<br>- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានដឹកនាំប្រតិភូក្រុមការងារលេខាធិការដ្ឋានខេត្ត នៅទីក្រុងហូជីមិញ ប្រទេសវៀតណាម ស្តីពីសហប្រតិបត្តិការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានកិច្ចសហការគាំទ្រ ដោយអង្គការសន្តិសេនា ។ |
| ខេត្តប៉ៃលិន | - ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ បានសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលដល់ក្រុមហ៊ុន SOK-LEAP METREY CO.LTD ដែលបានបញ្ជូនពលករទៅធ្វើការនៅប្រទេសថៃ ចំនួន០១លើក មាន ពលករចំនួន១៥នាក់ ស្រីចំនួន០៥នាក់ ។<br>- បានសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលដល់ក្រុមហ៊ុន CATM ASIA MANPOWER COOPERATION CO.LTD & B.S.R.O BEST MANPOWER CO.LTD ដែលបាន បញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសថៃ ចំនួន០៤លើក មានពលករ ចំនួន១៧៦នាក់ ស្រីចំនួន៦៨ នាក់ ។<br>- ក្រុមការងារសហប្រតិបត្តិការអន្តរជាតិ បានសហការជាមួយអាជ្ញាធរថៃ ជួយសម្រួលដល់ក្រុមហ៊ុនដែល បានបញ្ជូនពលករខ្មែរទៅធ្វើការនៅប្រទេសថៃ បានចំនួន០៧លើក មានពលករចំនួន២០៨នាក់ស្រីចំនួន ៨៥នាក់ ។ |

## ២.ខ. ៧.កិច្ចការកុមារ

សកម្មភាពខិតខំប្រឹងប្រែង ក្នុងកិច្ចការការពារ និងជួយសង្គ្រោះដល់កុមារជាពិសេសកុមារងាយរង គ្រោះដោយអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្មរបស់គ.រ.ប.ជ/គ.ខ.ប.ជ សរុបបានចំនួន២៦នាក់(កុមារី១៩នាក់)៖

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកណ្តាល បានសហការជាមួយអង្គការការលែប កម្ពុជា ធ្វើសមាហរណកម្មកុមារីរងគ្រោះដោយការជួញដូរមនុស្ស ចំនួន០២នាក់ ឲ្យទៅនៅជាមួយក្រុមគ្រួសារ ក្នុងសហគមន៍វិញ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបន្ទាយមានជ័យ មន្ត្រីរបស់មន្ទីរសង្គមកិច្ច ០២នាក់ បានចុះទៅសម្ភាសដើម្បីកំណត់អត្តសញ្ញាណ ជនរងគ្រោះដោយអំពើជួញដូរមនុស្ស ក្នុង ចំណោមនិរទេសជនដែលអជ្ញាធរថៃបានបញ្ជូនមករាល់ថ្ងៃ ត្រូវនឹងលក្ខណៈវិនិច្ឆ័យមានកុមារចំនួន ០៥នាក់(កុមារីចំនួន០២នាក់) ជាជនងាយរងគ្រោះដោយអំពើជួញដូរមនុស្ស កុមារាចំនួន០២នាក់ និងកុមារីចំនួន០២នាក់ត្រូវបានធ្វើសមាហរណកម្មទៅសហគមន៍វិញ និងកុមារាចំនួន០១ នាក់បាន បញ្ជូនទៅស្នាក់នៅអង្គការ Hagar ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តស្វាយរៀង បានទទួលកុមាររងគ្រោះដោយអំពើ ជួញដូរកម្លាំងពលកម្ម ដែលបានធ្វើមានតុភូមិនិវត្តន៍ពីប្រទេសវៀតណាម ចំនួន១១នាក់(កុមារា០៥ កុមារី០៦នាក់)។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តកណ្តាល

-បានសហការជាមួយក្រសួងសង្គមកិច្ច និងប្រធាននាយកដ្ឋានប្រឆាំងការជួញដូរមនុស្ស បានធ្វើមាតុភូមិនិវត្តន៍ កុមារីជនជាតិវៀតណាម រងគ្រោះដោយអំពើជួញដូរមនុស្សចំនួន០៤នាក់ ពីអង្គការមេត្រីអន្តរជាតិដើម្បីអាស៊ី ទៅកាន់ប្រទេសវៀតណាមវិញ ។

-បានសហការជាមួយអង្គការមេត្រីអន្តរជាតិដើម្បីអាស៊ី បានធ្វើសមាហរណកម្មកុមារីចំនួន០៣នាក់ រងគ្រោះដោយអំពើជួញដូរមនុស្ស នៅស្រុកលើកដែក បន្ទាប់ពីបានទទួលសេវាថែទាំព្យាបាល និងបណ្តុះបណ្តាលវិជ្ជាជីវៈ ឲ្យទៅរស់នៅជួបជុំជាមួយឪពុកម្តាយវិញ ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្តបាត់ដំបង បានទទួលក្មេងស្រីរងគ្រោះដោយករណីជួញដូរពលកម្មពីប្រទេសថៃចំនួន០១នាក់ ទៅមណ្ឌលអង្គការ HAGAR ដើម្បីទទួលសេវាថែទាំសុខភាព ។

+មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ខេត្ត បន្ទាយមានជ័យ បានចុះជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ឲ្យស្នាក់នៅរយៈពេលខ្លី នៅមណ្ឌលស្តារនីតិសម្បទា ចំនួន១០នាក់(ក្នុងនោះមាន កុមារ០៩នាក់ និងកុមារីចំនួន០១នាក់) ។

## ២.គ. ការងារសម្របសម្រួល

ការងារដឹកនាំសម្របសម្រួល ផ្ទៃក្នុងស្ថាប័ន អន្តរស្ថាប័ន និងជាមួយទីភ្នាក់ងារអន្តរជាតិ ក្នុងត្រីមាសទី៣នេះ សរុបបានចំនួន៤៣លើកៈ ដោយគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស(គ.ជ.ប.ជ) ចំនួន ២២លើក, ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាចំនួន០៦លើក, និងដោយលេខាធិការដ្ឋានរាជធានី/ខេត្ត ចំនួនចំនួន១៥លើក ដូចបានបរិយាយខាងក្រោមៈ

*តារាងការងារដឹកនាំ និងសម្របសម្រួល កិច្ចសហការ*

| ស្ថានប័ន សម្របសម្រួល | ចំនួនសកម្មភាព |
|---|---|
| គណៈកម្មាធិការជាតិ គ.ជ.ប.ជ | ➢ ការងារសម្របសម្រួល និងកិច្ចប្រជុំចំនួន ចំនួន២២លើក ៖ |
| លោកជំទាវ អនុប្រធាន អចិន្ត្រៃយ៍ និង អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ | - បានអញ្ជើញជាគណៈអធិបតីក្នុងកិច្ចប្រជុំអន្តរក្រសួង ពិភាក្សាលើសេចក្តីព្រាងសេចក្តីថ្លែងការណ៍ ស្តីពីការពង្រឹងការឆ្លើយតបនឹងវិបត្តិទេសន្តរប្រវេសន៍ និងការជួញដូរមនុស្ស នៅសាលប្រជុំអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បានអញ្ជើញជួបពិភាក្សាការងារ ជាមួយលេខាទទួលបន្ទុកផ្នែកអន្តោ ប្រវេសន៍ របស់ស្ថានទូតអូស្ត្រាលីប្រចាំកម្ពុជាចំនួន ០២រូប លោកស្រី ភីឡា ដេវីដសាន់ និងលោក អាដុន ប៊ីសេន ស្តីពី Bali Process on Business នៅទីស្តីការក្រសួងមហាផ្ទៃ ។<br>- បានដឹកនាំកិច្ចប្រជុំពិភាក្សាអន្តរក្រសួង ស្តីពីការរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅសាលប្រជុំអគ្គ លេខាធិការដ្ឋាន គ.ជ.ប.ជ ។<br>- បានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំពិគ្រោះយោបល់ជាមួយក្រសួង ស្ថាប័ន ដៃគូពាក់ព័ន្ធ ស្តីពីការធ្វើមូល |

ដ្ឋានីយកម្មគោលដៅទី៥ និងគោលដៅផ្សេងទៀត គោលដៅអភិវឌ្ឍន៍ប្រកប ដោយចីរភាព (គ.អ.ច) ២០១៦-២០៣០ នៅទីស្តីការក្រសួងកិច្ចការនារី ។

- ក្នុងនាមជាអនុប្រធានសមាគមន៍នារីកម្ពុជា ដើម្បីសន្តិភាព និងអភិវឌ្ឍន៍ បានអញ្ជើញជាអធិបតីក្នុងពិធីសំណេះសំណាលជាមួយបងប្អូនមន្ត្រីរាជការជានារី ថ្នាក់ខេត្ត ស្រុក និងឃុំ ចំនួន ៧៥នាក់ នៅស្រុកមង្គល បូរី ខេត្តបន្ទាយមានជ័យ ។
- បានដឹកនាំរៀបចំកិច្ចប្រជុំអន្តរក្រសួង-ស្ថាប័ន ស្តីពីកិច្ចប្រជុំដកបទពិសោធន៍ លើការងារគ្រប់គ្រងលំហូរមិនប្រក្រតី នៃពលករឆ្លងកាត់ព្រំដែន ក្រោមធិបតីភាពដ៏ខ្ពង់ខ្ពស់ សម្តេច ក្រឡាហោម ស ខេង **ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធានគណៈកម្មាធិការជាតិ ប្រយុទ្ធប្រឆាំងអំពើជួញដូរ**មនុស្ស(គ.ជ.ប.ជ) នៅសាលាខេត្តបន្ទាយមានជ័យ ដែលមានសមាសភាពចូលរួមសរុបជាង ២០០ នាក់ ។
- បានអញ្ជើញជាតំណាងក្រសួងមហាផ្ទៃ ក្នុងពិធីចុះហត្ថលេខា លើអនុស្សរណៈនៃការយោគយល់ រវាងអង្គការការពារកុមារ នៃអង្គការមូលនិធិដើម្បីកុមារកម្ពុជា(CPU) និង ក្រសួងមហាផ្ទៃ ស្តីពីការរួមចំណែកដើម្បីមនុស្សធម៌ នៅទីស្តីការក្រសួងមហាផ្ទៃ ។
- បានដឹកនាំកិច្ចប្រជុំ ស្តីពីការចាត់វិធានការនៃលំហូរពលករឆ្លងដែន និងការអនុវត្តជំនាញនៃក្រុមជំនួយកិច្ចការទាំង៦ នៃគណៈកម្មាធិការជាតិ គ.ជ.ប.ជ នៅទីស្តីការ គ.ជ.ប. ។
- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីត្រៀមរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួងត្រៀមរៀបចំកិច្ចប្រជុំទ្វេភាគីចិន-កម្ពុជា ដើម្បីពិភាក្សាសម្រេចលើកិច្ចព្រមព្រៀង ស្តីពីកិច្ចសហប្រតិបត្តិការក្នុងការបង្ការទប់ស្កាត់ និងប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- បានដឹកនាំអគ្គលេខាធិការដ្ឋានគ.ជ.ប.ជទទួលជួបសំដែងការគួរសម និងពិភាក្សាការងារជាមួយគណៈប្រតិភូខេត្តចាំងស៊ីប្រទេសចិន ដែលអញ្ជើញមកបំពេញទស្សនៈកិច្ចនៅកម្ពុជា ដើម្បីចែករំលែកនូវបទពិសោធន៍ការងារទៅវិញទៅមក ជំរុញឲ្យកិច្ចសហប្រតិបត្តិការក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សមានភាពកាន់តែល្អប្រសើរ នៅទីស្តីការក្រសួងមហាផ្ទៃ ។
- បានជួបប្រជុំពិភាក្សាការងារជាមួយអង្គការ Winrock នៅទីស្តីការ គ.ជ.ប.ជ ។ និងនៅពេលរសៀលបានទទួលជួបពិភាក្សាការងារជាមួយលោក William A.Heidt ឯកអគ្គរដ្ឋទូតអាមេរិកប្រចាំកម្ពុជា ក្នុងគោលបំណងដកស្រង់បទពិសោធន៍ការងារ ស្តីពីការអនុវត្តផែន យុទ្ធសាស្ត្រប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឆ្នាំ២០១៦ នៅទីស្តីការ គណៈកម្មាធិការជាតិ គ.ជ.ប.ជ ។
- បានដឹកនាំកិច្ចប្រជុំអន្តរក្រសួង ដើម្បីត្រៀមរៀបចំវគ្គបណ្តុះបណ្តាល ស្តីពីបែបបទ និងនីតិវិធីនៃការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ។
- បានដឹកនាំរៀបចំពិធីចុះហត្ថលេខាលើអនុស្សរណៈនៃការយោគយល់ គ្នារវាង គ.ជ.ប.ជ ជាមួយអង្គការអ្នកស្ម័គ្រចិត្តស៊ីវិល (GVC) ស្តីពីគម្រោង Migra-Action ការតស៊ូមតិ ការតាមដាន និងការប្រាស្រ័យទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងទេសន្តរប្រវេសន៍ ដោយមិនសុវត្ថិភាពនៅកម្ពុជា នៅអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ ថ្ងៃទី២៩ ខែសីហា ឆ្នាំ២០១៦ ។
- បានអញ្ជើញជាវាគ្មិន ក្នុងសន្និសីទស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព និងបទបង្ហាញអំពីមេរៀន

| | |
|---|---|
| | យល់ដឹងពីអំពើជួញដូរមនុស្ស ដែលរៀបចំដោយអង្គការ Maritan's Purse នៅសណ្ឋាគារហ៊ីម៉ាវ៉ារី ។<br>- បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំអំពីតួនាទី និងភារកិច្ចរបស់លេខា ធិការដ្ឋាន នៃអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នៅសាលប្រជុំគ.ជ.ប.ជ ។<br>- បានអញ្ជើញជាអធិបតីក្នុងកិច្ចប្រជុំ ស្តីពីការរៀបចំវិធានការគ្រប់គ្រងលំហូរមិនប្រក្រតីនៃពលករឆ្លងកាត់ព្រំដែន នៅសាលប្រជុំគ.ជ.ប.ជ ។<br>- បានអញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គ បិទវគ្គ និងជាគ្រូឧទ្ទេសនៃវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលមានរយៈពេល ៤ថ្ងៃ រៀបចំដោយ គ.ជ.ប.ជ នៅទីស្តីការក្រសួងមហាផ្ទៃ។<br>- បានអញ្ជើញជាវាគ្មិន ក្នុងកិច្ចពិភាក្សាជំនាញស្តីពីការប្រយុទ្ធប្រឆាំង អំពើកេងប្រវ័ញ្ច និងអំពើរំលោភបំពានផ្លូវភេទលើកុមារតាមប្រព័ន្ធអ៊ីនធឺណេត ដើម្បីឲ្យអ៊ីនធឺណេតជា កន្លែងដែលកាន់តែមានសុវត្ថិភាព រៀបចំដោយអង្គការ APLE នៅសណ្ឋាគារ InterContinental ។<br>- បានអញ្ជើញជាគណៈអធិបតី ក្នុងពិធីធ្វើបទបង្ហាញរបាយការណ៍ស្រាវជ្រាវអំពីលំអាន និងការអនុវត្តនៃការធ្វើចំណាកស្រុកក្នុងប្រទេសសម្រាប់និយោជិត ដែលមានកម្រិតទាប និងគ្មានជំនាញនៅប្រទេសកម្ពុជា រៀបចំដោយវិទ្យាស្ថានបើកទូលាយ នៅសណ្ឋាគារកាំបូឌីយ៉ាណា ។<br>- បានអញ្ជើញចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីស្ត្រី និងភាពជាអ្នក ដឹកនាំ នៅប្រទេសសិង្ហបុរី ។<br>- បានអញ្ជើញជាអធិបតីក្នុងពិធីបើកវគ្គ បិទវគ្គ និងជាគ្រូឧទ្ទេសនៃវគ្គបណ្តុះបណ្តាលគ្រូបង្គោល ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប ដែលមានរយៈពេល ៣ថ្ងៃ រៀបចំដោយ គ.ជ.ប.ជ នៅសាលាខេត្តកណ្តាល ។<br>- បានអញ្ជើញជាអធិបតីក្នុងវេទិកា សំឡេងអតីតជនរងគ្រោះដោយអំពើ ជួញដូរមនុស្ស រៀបចំដោយអង្គការ WINROCK International នៅសណ្ឋាគារប៉ារ៉ាឌី ខេត្តសៀមរាប ។ |
| អន្តរក្រសួង | ➢ ការងារសម្របសម្រួល និងកិច្ចប្រជុំចំនួន០៦លើក |
| ក្រសួងសង្គមកិច្ច | - បានចូលរួមកិច្ចប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីយុត្តិធម៌អនីតិជន និងបូកសរុបការងារឆមាសទី១ឆ្នាំ២០១៦ និងទិសដៅបន្ត ។<br>- បានចូលរួមចែករំលែកព័ត៌មាន អំពីទស្សនៈវិស័យ និងសកម្មភាពការងារដែលក្រសួងបានអនុវត្តពាក់ព័ន្ធ និងអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារ ក្នុងកិច្ចពិភាក្សាដោះស្រាយអំពើកេងប្រវ័ញ្ចផ្លូវភេទកុមារតាមប្រព័ន្ធអ៊ីនធឺណេត ។<br>- បានចូលរួមកិច្ចប្រជុំពិភាក្សាលើឯកសារបណ្តុះបណ្តាលគ្រូឧទ្ទេស ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប និងផែនការបណ្តុះបណ្តាល ។<br>- រៀបចំបណ្តុះបណ្តាល ស្តីពី(បទដ្ឋានអប្បបរមាសម្រាប់ថែទាំជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមណ្ឌល) និង( ឧបករណ៍ត្រួតពិនិត្យ និងវាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធជនរងគ្រោះដោយអំពើជួញដូរមនុស្ស) ដែលមានអ្នកចូលរួម សរុបចំនួន៦៥នាក់ (ស្រីចំនួន៣១នាក់) ក្នុងនោះមកពីបណ្តាមន្ទីរ ស.អ.យ ២៥រាជធានីខេត្ត និងអង្គការពាក់ព័ន្ធចូលរួមចំនួន១៧នាក់ នៅខេត្តសណ្ឋាគារប្រេស៊ីដង់ បាត់ដំបង ។<br>- បានសហការជាមួយអង្គការចាប់ដៃគូ ចូលរួមជាគ្រូឧទ្ទេស ក្នុងវគ្គបណ្តុះបណ្តាលលើប្រធានបទ ស្តីពីនីតិវិធីធ្វើសមាហរណកម្មជនរងគ្រោះទៅកាន់សហគមន៍វិញ ដែលមានអ្នកចូលរួម សរុបចំនួន១៩១នាក់ (ស្រីចំនួន១១២នាក់) និងមានអង្គការចូលរួមចំនួន៣០អង្គការ ។<br>- បានចូលរួមកិច្ចប្រជុំ ស្តីពីលំហូរមិនប្រក្រតីនៃពលករឆ្លងដែន ចំនួន០១លើកនៅសាលាខេត្តបន្ទាយ |

| | |
|---|---|
| | មានជ័យ។ |
| រាជធានី/ខេត្ត | ➢ ការងារសម្របសម្រួល និងកិច្ចប្រជុំចំនួន១៥លើក |
| រាជធានីភ្នំពេញ | - ស្នងការដ្ឋាននគរបាលរាជធានីភ្នំពេញ បានចាត់ឲ្យមន្ត្រីថ្នាក់ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស ចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការអភិវឌ្ឍក្រមសីលធម៌យេនឌ័រ ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ។ |
| ខេត្តឧត្តរមានជ័យ | - ក្រុមលេខាធិការដ្ឋាននៃគណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បានរៀបចំការប្រជុំបូកសរុបប្រចាំឆមាសទី១ ឆ្នាំ២០១៦ និងទិសដៅអនុវត្តបន្ត ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់មន្ត្រីលេខាធិការដ្ឋាន ដើម្បីអនុវត្តផ្សព្វផ្សាយបន្តជូនប្រជាពលរដ្ឋនៅតាមមូលដ្ឋាន ។ |
| ខេត្តបន្ទាយមានជ័យ | - ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានចាត់បញ្ជូនមន្ត្រីជំនាញ០៣រូប ប្រចាំការនៅតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីសម្ភាសពលករ ដែលអាជ្ញាធរថៃបញ្ជូនមក និងស្រាវជ្រាវរកមុខសញ្ញា ពាក់ព័ន្ធអំពើជួញដូរមនុស្ស ។<br>- បានចូលរួមប្រជុំរៀបចំគម្រោងគ្រប់គ្រោងថវិកាសម្រាប់ឆ្នាំ២០១៦ បានចំនួន០១លើក ដោយមានការចូលរួមប្រជុំ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីលំហូរមិនប្រក្រតីពលករឆ្លងកាត់ព្រំដែន នៅសាលាខេត្តបន្ទាយមាន ជ័យ ។<br>- ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានចាត់បញ្ជូនមន្ត្រីជំនាញ០៣រូប ប្រចាំការនៅតាមច្រកទ្វារអន្តរជាតិប៉ោយប៉ែត ដើម្បីសម្ភាសពលករ ដែលអាជ្ញាធរថៃបញ្ជូនមក និងស្រាវជ្រាវរកមុខសញ្ញា ពាក់ព័ន្ធអំពើជួញដូរមនុស្ស ។<br>- បានចូលរួមប្រជុំរៀបចំគម្រោងគ្រប់គ្រោងថវិកាសម្រាប់ឆ្នាំ២០១៦ បានចំនួន០១លើក ដោយមានការចូលរួមប្រជុំ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីលំហូរមិនប្រក្រតីពលករឆ្លងកាត់ព្រំដែន នៅសាលាខេត្តបន្ទាយមាន ជ័យ ។<br>- ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំឆមាសទី១ ប្រចាំខែកញ្ញា ឆ្នាំ២០១៦ ក្រោមអធិបតីភាពលោកស្រី ប៊ុក ណាឌីអភិបាលរងខេត្ត និងជាប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ដែលមានសមាសភាពចូលរួមចំនួន៨០នាក់ ស្រីចំនួន៣៦នាក់ ។<br>- បានចូលរួមប្រជុំរៀបចំគម្រោងថវិកាសម្រាប់ឆ្នាំ២០១៧ បានចំនួន០១លើក ដោយមានការចូលរួមប្រជុំ ពីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ ស្តីពីលំហូរមិនប្រក្រតីពលករឆ្លងកាត់ព្រំដែន នៅសាលាខេត្តបន្ទាយមាន ជ័យ ។<br>- លេខាធិការដ្ឋាននៃគណៈកម្មាធិការ គ.ខ.ប.ជ ខេត្តបានចូលរួមសិក្ខាសាលា ស្តីពីការធ្វើចំណាកស្រុកដោយសុវត្ថិភាព បានចំនួន១វគ្គ ដែលរៀបដោយអង្គការ DI FI ។ |
| ខេត្តបាត់ដំបង | - បានចូលរួមធ្វើបទបង្ហាញអនុក្រឹត្យលេខ ១៩០ របស់រាជរដ្ឋាភិបាល និងប្រកាសបំពេញបន្ថែមចំនួន០៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបើកវគ្គបណ្តុះបណ្តាល គ្រូឧទ្ទេសនៅក្នុងគម្រោង " ចំណាកស្រុកប្រកបដោយសុវត្ថិភាព " របស់អង្គការហ្វាពន្លឺសិល្បៈ សហការជាមួយអង្គការកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ ធ្វើនៅសណ្ឋាគារស្ទឹងផាក ខេត្តបាត់ដំបងបានចំនួន០២លើក សមាសភាពចូលចំនួន៧០នាក់ស្រីចំនួន១៩នាក់។<br>- បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពី(បទដ្ឋានអប្បបរមាសម្រាប់ថែទាំជនរងគ្រោះ ដោយអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីកម្មផ្លូវភេទ ដែលស្នាក់នៅក្នុងមណ្ឌល )និង( ឧបករណ៍ត្រួតពិនិត្យ និង |

| | |
|---|---|
| | វាយតម្លៃការអនុវត្តគោលនយោបាយ និងបទដ្ឋានអប្បបរមា ស្តីពីកិច្ចការពារសិទ្ធជនរងគ្រោះដោយអំពើជួញដូរមនុស្ស) មានអ្នកចូលរួម សរុបចំនួន៧៦នាក់ (ស្រីចំនួន១១នាក់) រៀបដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា នៅសណ្ឋាគារប្រេស៊ីដង់ ខេត្តបាត់ដំបង ។<br>- បានចូលរួមធ្វើបទបង្ហាញអនុក្រឹត្យលេខ ១៩០ របស់រាជរដ្ឋាភិបាល និងប្រកាសបំពេញបន្ថែមចំនួន០៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ក្នុងការបើកវគ្គបណ្តុះបណ្តាល គ្រូឧទ្ទេសនៅក្នុងគម្រោង " ចំណាកស្រុកប្រកបដោយសុវត្ថិភាព " របស់អង្គការហ្វាពន្លឺសិល្បៈ សហការជាមួយអង្គការកម្ពុជា ដើម្បីជួយស្ត្រីមានវិបត្តិ ធ្វើនៅសណ្ឋាគារស្ទ្រឹងផាក ខេត្តបាត់ដំបងបានចំនួន០១លើក សមាសភាពចូលចំនួន៣៥នាក់ស្រីចំនួន១៦នាក់ (មកពីឃុំព្រៃខ្ពស់ ឃុំល្វា ស្រុកបវេល) នៅថ្ងៃទី១៦-១៧ ខែសីហា ឆ្នាំ២០១៦ ។<br>- បានចូលរួមជាវាគ្មិននៅក្នុងទិវាពិគ្រោះយោបល់ ស្តីពីការទប់ស្កាត់ និងលុបបំបាត់ពលកម្មកុមារថ្នាក់ខេត្ត តាម រយៈការអប់រំ និងលើកកម្ពស់ជីវភាពរស់នៅ ធ្វើនៅសណ្ឋាគារខេមរា ខេត្តបាត់ដំបងបានចំនួន០១លើក មានសមាសភាពចូលចំនួន១១៩នាក់ ស្រីចំនួន៦៩នាក់ ។<br>- បានចូលរួមវគ្គសិក្ខាសាលា ស្តីពីការឆ្លុះបញ្ចាំងលើគម្រោងលុបបំបាត់ពលកម្មកុមារ សហការរៀបចំដោយអង្គការអភិវឌ្ឍជីវភាពកសិករ ធ្វើនៅសាលប្រជុំសកលវិទ្យាល័យជាតិ និងសេដ្ឋកិច្ច UME ខេត្តបាត់ដំបងបានចំនួន០១លើក សមាសភាពចូលចំនួន៣៧នាក់ស្រីចំនួន១៥នាក់ ។ |
| ខេត្តប៉ៃលិន | - គណៈកម្មាធិការ គ.ខ.ប.ជ ខេត្តបានចូលរួមប្រជុំប្រចាំខែរបស់ គ.ក.ស.ក ស្តីពីរបាយការណ៍ទប់ស្កាត់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំខែតាមភូមិនីមួយៗនៅក្នុងសង្កាត់ ៖នៅសាលាសង្កាត់បយ៉ាខា និងសាលាសង្កាត់ប៉ៃលិន មានអ្នកចូលរួមចំនួន២៨នាក់ ស្រីចំនួន២០នាក់ ។<br>- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្តបានចូលរួមប្រជុំលើកទី២៥ របស់គណៈកម្មាធិការពិគ្រោះយោបល់ស្ត្រី និងកុមារខេត្ត ស្តីពីការទប់ស្កាត់ការធ្វើចំណាកស្រុករបស់ប្រជាពលរដ្ឋ មានអ្នកចូលរួមចំនួន២៣នាក់ ស្រីចំនួន១២នាក់ ។<br>- លោកជំទាវ ជា លាក បានចូលរួមប្រជុំ ស្តីពីលំហូរមិនប្រក្រតីនៃពលករចំណាកស្រុកខុសច្បាប់នៅខេត្ត បន្ទាយមានជ័យ ក្រោមអធិបតីភាព *សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ និងជាប្រធាន គ.ជ.ប.ជ ។*<br>- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្តបានចូលរួមប្រជុំប្រចាំខែរបស់ គ.ក.ស.ក ស្តីពីការទប់ស្កាត់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ការធ្វើចំណាកស្រុកខុសច្បាប់ប្រចាំខែ នៅតាមសង្កាត់និមួយៗបានចំនួន០៤លើក មានអ្នកចូលរួមចំនួន៧៣នាក់ ស្រីចំនួន៤៩នាក់ ។ |
| ខេត្តសៀមរាប | - លេខាធិការដ្ឋាន គ.ខ.ប.ជ. ខេត្ត បានរៀបចំកិច្ចប្រជុំប្រចាំខែដែលមានសមាភាពមកពីបណ្តាមន្ទីរនានា អង្គភាពពាក់ព័ន្ធ អាជ្ញាធរមូលដ្ឋាន និងអង្គការដៃគូមិនមែនរដ្ឋាភិបាលជាតិ-អន្តរជាតិ ដើម្បីរួមគ្នាប្រយុទ្ធប្រឆាំងនឹងបទល្មើសផ្សេងៗ ដូចជាការកេងប្រវ័ញ្ចកម្លាំងពលកម្មលើកុមារ ការធ្វើអាជីកម្មផ្លូវភេទ ការប្រឆាំងអំពើជួញដូរមនុស្ស ដែលមានអ្នកចូលរួមចំនួន៣៦នាក់ ស្រីចំនួន២០នាក់។<br>- ឯកឧត្តមអភិបាលខេត្ត ជាប្រធាន គ.ខ.ប.ជ. ខេត្ត លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ. បានជួបប្រជុំ ជាមួយប្រតិភូក្រុមប្រឹក្សាជាតិកម្ពុជាដើម្បីស្ត្រី ស្តីពីការតាមដានការអនុវត្តអនុសញ្ញាការលុបបំបាត់រាល់ទម្រង់ នៃការរើសអើងប្រឆាំងនឹងនារីភេទ ស៊ី-ដ និងអនុសាសន៍ដ៏ខ្ពង់ខ្ពស់របស់សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា និងច្បាប់ជាតិពាក់ព័ន្ធនានា នៅថ្ងៃទី២៧-២៨ ខែកក្កដា ឆ្នាំ២០១៦ ។ |

៥២៧

| | |
|---|---|
| | - មន្ទីរអប់រំយុវជន និងកីឡាខេត្ត បានប្រជុំប្រចាំខែ ជាមួយការិយាល័យអប់រំយុវជន និងកីឡា ក្រុង ស្រុក និងសាលាក្រោមឱវាទ ដោយបានជំរុញឲ្យធ្វើការបញ្ជ្រាបការផ្សព្វផ្សាយច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និង អំពើធ្វើអាជីកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់មន្ត្រីអប់រំ លោកគ្រូ អ្នកគ្រូ និងសិស្សានុសិស្ស តាមរយៈ<br>- រាល់ពេលពិធីគោរពទង់ជាតិ ការប្រជុំបច្ចេកទេស ការប្រារព្ធកម្មវិធីតូច ធំនៅក្នុងនិងក្រៅសាលារៀន ។<br>- ផ្សព្វផ្សាយតាមរយៈមិត្តអប់រំមិត្ត និងក្លឹបសិក្សា។<br>- ស្នងការរងខេត្ត តំណាងកងរាជអាវុធហត្ថខេត្ត មន្ទីរពាក់ព័ន្ធ និងអង្គការដៃគូ បានចូលរួមប្រជុំ ស្តីពីបទដ្ឋាន អប្បបរមាកិច្ចការពារសិទ្ធិជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលរៀបចំដោយក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ។<br>- លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានជួបប្រជុំ បានចូលរួមក្នុងពិធីចុះហត្ថលេខាអនុស្សរណៈនៃការយោគយោល់គ្នារវៀងគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងអង្គការអ្នកស្ម័គ្រស៊ីវិល ស្តីពីគម្រោងមីហ្គ្រាអែកស៊ិន នៅក្រសួងមហាផ្ទៃ ។<br>- មន្ទីរព័ត៌មានខេត្ត បានសហការជាមួយអង្គភាពជុំវិញខេត្ត អាជ្ញាធរដែនដី ភូមិ ឃុំ សង្កាត់ ក្រុង ស្រុក និងអង្គការពាក់ព័ន្ធ ចូលរួមធ្វើជាវាគ្មិន ដើម្បីផលិតកម្មវិធី សន្ទនាមតិ និងកម្មវិធីយើងធ្វើបាន ដើម្បីធ្វើការផ្សព្វផ្សាយ ស្តីពីបញ្ហាអំពើហិង្សាក្នុងគ្រួសារ និងការធ្វើចំណាកស្រុកខុសច្បាប់ ពិសេស គឺការស្វែងរកជំនួយពីអាជ្ញាធរ និងសង្គមស៊ីវិល នៅក្នុងខេត្ត ។<br>- ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន នៃស្នងការនគរបាលខេត្ត បានចូលរួមផ្សព្វផ្សាយច្បាប់ពាក់ព័ន្ធអំពើជួញដូរមនុស្ស តាមវិទ្យុ បានចំនួន០៤លើក ។<br>- លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមវេទិកា ស្តីពីសំឡេងអតីតជនរងគ្រោះ នៃអំពើជួញដូរមនុស្ស ក្រោមអធិបតីភាព លោកជំទាវ ជូ ប៊ុអេង រដ្ឋលេខាធិការធិការក្រសួងមហាផ្ទៃ និងជាអនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ ដែលរៀបដោយអង្គការវីនរ៉ក់អន្តរជាតិ នៅសណ្ឋាគារអង្គរប៉ារ៉ាឌី ។<br>- លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំ ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៦ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដែលមានការចូលរួមពីសមាជិក គ.ខ.ប.ជ និងអង្គការដៃគូពាក់ព័ន្ធសរុបចំនួន៣៩នាក់ ស្រី១៨ចំនួននាក់។ |
| **ខេត្តកំពង់ធំ** | - បានចូលរួមកិច្ចប្រជុំត្រួតពិនិត្យការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើអាជីកម្មផ្លូវភេទ ប្រចាំឆមាសទី១ ឆ្នាំ២០១៦ នៅសាលប្រជុំនាយកដ្ឋានប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន ។<br>- លេខាធិការដ្ឋាននៃគណៈកម្មាធិការ គ.ខ.ប.ជ ខេត្តបានចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការអភិវឌ្ឍក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានចំនួន០១លើករយៈពេល០២ថ្ងៃ នៅសណ្ឋាគារកាំបូឌីយ៉ាណា។ |
| **ខេត្តស្ទឹងត្រែង** | - មន្ទីរសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទាខេត្ត បានសហការជាមួយអង្គការ VCAO ស្តីពីការតស៊ូមតិរបស់ស្ត្រី និងកុមារ របស់គណៈកម្មាធិការការពារកុមារ ក្នុងនោះមានក្របខ័ណ្ឌច្បាប់ ក្របខ័ណ្ឌគោលនយោបាយ ក្របខ័ណ្ឌជាតិ លិខិត បទដ្ឋាន និងយន្តការ នៅក្រសួងសង្គកិច្ច ដែលមានអ្នកចូលរួមចំនួន៦៥នាក់ ស្រីចំនួន២១នាក់ ។ |
| **ខេត្តក្រចេះ** | - បានរៀបចំកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋាន គ.ជ.ប.ជ ខេត្ត ស្តីពីការអនុវត្តការងារប្រយុទ្ធ |

| | |
|---|---|
| | ប្រឆាំងអំពើជួញដូរ មនុស្សប្រចាំខែកក្កដា ឆ្នាំ២០១៦ មានសមាសភាពចូលរួមចំនួន២២៨នាក់ ស្រីចំនួន១១២នាក់ ។<br>-បានរៀបចំកិច្ចប្រជុំក្រុមការងារលេខាធិការដ្ឋាន គ.ជ.ប.ជ ខេត្ត ស្តីពីការអនុវត្តការងារប្រយុទ្ធប្រឆាំងអំពើជួញដូរ មនុស្សប្រចាំខែសីហា ឆ្នាំ២០១៦ មានសមាសភាពចូលរួមចំនួន០៧នាក់ ស្រីចំនួន០២នាក់ ។ |
| ខេត្តកំពង់ចាម | -ក្រុមការងារការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីសុវត្ថិភាពកុមារ ក្នុងវិស័យទេសចរណ៍ នៅមន្ទីរទេសចរណ៍ខេត្តកំពង់ចាម ។<br>-លោកស្រី ស្នងការរង អៀម វណ្ណី ស្នងការរងទទួលបន្ទុក និងក្រុមការងារថ្នាក់ការិយាល័យប្រឆាំងអំពើជួញដូរមនុស្ស និងការពារអនីតិជន បានចូលរួមសិក្ខាសាលាថ្នាក់ជាតិ ស្តីពីការអភិវឌ្ឍក្រមសិលធម៌យេនឌ័រ ក្នុងការប្រឆាំងអំពើជួញដូរមនុស្ស នៅសណ្ឋាគារកាំបូឌីយ៉ាណា រាជធានីភ្នំពេញ ។ |
| ខេត្តត្បូងឃ្មុំ | -លេខាធិការដ្ឋាន គ.ជ.ប.ជ ខេត្ត បានសហការជាមួយអង្គការស៊ីកាស្វា រៀបចំកិច្ចប្រជុំបូកសរុបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ប្រចាំត្រីមាសទី៣ ឆ្នាំ២០១៦ និងទិសដៅត្រីមាសទី៤ ដែលមានសមាសភាពចូលរួម ពីលេខាធិការ គ.ជ.ប.ជ ,ក្រុមការងារជំនាញទាំង៦ ,អភិបាលរងទទួលបន្ទុកការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ,ក្រុង ស្រុកទាំង៧ ,អធិការដ្ឋាននគរបាលក្រុង ស្រុក និងមន្ទីរកិច្ចការនារីក្រុង ស្រុក មានអ្នកចូលរួមចំនួន៥៤នាក់ ស្រីចំនួន១៧នាក់ ។ |
| ខេត្តកណ្តាល | -ក្រុមការងារថ្នាក់ស្រុក បានប្រជុំការងារផ្សព្វផ្សាយ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាក ស្រុកប្រកបដោយសុវត្ថិភាព ចំនួន០១លើកដែលមានប្រជាជនចូលរួមចំនួន៧០នាក់ ស្រីចំនួន៣៩នាក់ ។<br>-ក្រុមការងារថ្នាក់ស្រុក បានចូលរួមប្រជុំជាមួយអង្គការមូលនិធិសិទ្ធិកុមារ និងបានបញ្ជ្រាបការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ចំនួន០២លើក នៅឃុំក្រាំងម្កាក់ និងឃុំទួលព្រេជ មានអ្នកចូលរួមចំនួន១៩៦នាក់ ស្រីចំនួន៨៧នាក់ ។<br>-ក្រុមការងារថ្នាក់ស្រុក គ.ក.ស.ក បានធ្វើកិច្ចប្រជុំប្រចាំខែ ជំរុញឲ្យជនបង្គោលកិច្ចការនារីឃុំទាំង១៨បន្តសកម្មភាពផ្សព្វផ្សាយច្បាប់ ស្តីពីការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកខុសច្បាប់ ដល់ប្រជាពលរដ្ឋយល់ដឹង កុំឲ្យចាញ់បោកឃោសនារបស់ជនខិលខូចមួយចំនួនតូច ដែលមានអ្នកចូលរួមចំនួន៥១នាក់ ស្រីចំនួន៣៥នាក់ ។<br>-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈបានធ្វើការប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ថ្នាក់ដឹកនាំ និងក្រុមការងារនៅក្នុងមន្ទីរ ដែលមានអ្នកចូលរួមចំនួន៥៨នាក់ ស្រីចំនួន២៣នាក់ ។<br>-ក្រុមការងារថ្នាក់ស្រុក គ.ក.ស.ក បានធ្វើកិច្ចប្រជុំប្រចាំខែ ជំរុញឲ្យមន្ត្រីថ្នាក់ស្រុកយកចិត្តទុកដាក់លើស្ថានភាពស្ត្រី និងកុមារ ធ្វើសកម្មភាពផ្សព្វផ្សាយ ស្តីពីការធ្វើចំណាកស្រុកខុសច្បាប់ ដល់ប្រជាពលរដ្ឋយល់ដឹង កុំឲ្យចាញ់បោកឃោសនារបស់ជនខិលខូចមួយចំនួនតូច ដែលមានអ្នកចូលរួមចំនួន២៥នាក់ ស្រីចំនួន២០នាក់ ។<br>-មន្ទីរវប្បធម៌ និងវិចិត្រសិល្បៈបានធ្វើការប្រជុំផ្សព្វផ្សាយច្បាប់ ស្តីពីប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទលើស្ត្រី និងកុមារ ដល់ថ្នាក់ដឹកនាំ និងក្រុមការងារនៅក្នុងមន្ទីរ ដែលមានអ្នកចូលរួមចំនួន៥៨នាក់ ស្រីចំនួន២៣នាក់ ។ |
| ខេត្តព្រៃវែង | -លេខាធិការដ្ឋាន គ.ជ.ប.ជ ខេត្ត បានចូលរួមប្រជុំជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងជាមួយឯកឧត្តម ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកប្រចាំប្រទេសកម្ពុជា ស្តីពីការវាយតម្លៃរបស់ ឯក |

| | |
|---|---|
| | ឧត្តម ឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិកលើការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស នៅក្នុងប្រទេសកម្ពុជា។ ជាពិសេសលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានជួបពិភាក្សាជាមួយឯកអគ្គរដ្ឋទូតសហរដ្ឋអាមេរិក ស្តីពីស្ថានភាពអំពើជួញដូរមនុស្សនៅក្នុងខេត្តព្រៃវែង និងការសំណូមពរឲ្យទូតសហរដ្ឋអាមេរិកជួយអ្វីខ្លះដល់ គ.ខ.ប.ជ ដើម្បីឲ្យការងារនេះមានប្រសិទ្ធភាពជាងមុន ។<br>-លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយស្នងការដ្ឋាន ចូលរួមប្រជុំជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ ខេត្ត ដើម្បីផ្សព្វផ្សាយអប់រំអំពីច្បាប់ និងលិខិតបទដ្ឋាននានា ដែលពាក់ព័ន្ធនឹងជំនាញការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ជូនដល់អង្គប្រជុំ ជាពិសេសដល់គណៈកម្មាធិការអភិបាលស្រុក និងក្រុមប្រឹក្សាឃុំ ឲ្យពួកគាត់ជួយផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋមូលដ្ឋានរបស់ខ្លួនតាមរយៈពិធីផ្សេង ។<br>-លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលជាវាគ្មិនក្នុងវេទិកា ស្តីពីសុវត្ថិភាពចំណាកស្រុក ចំនួន ០១លើក រយៈ ពេល០៥ថ្ងៃ លើស្រុកចំនួន០៥ ៖<br>• នៅវត្តទួលវាំង ឃុំស្មោងខាងត្បូង ស្រុកកំចាយមារ មានអ្នកចូលរួមចំនួន១០០នាក់ ស្រីចំនួន៧៤នាក់ ថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦។<br>• នៅសាលាបឋមសិក្សាការកូនសាត់ ភូមិការកូនសត្វ ឃុំបឹងដោល ស្រុកព្រះស្តេច មានអ្នកចូលរួមចំនួន១០០នាក់ ស្រីចំនួន៦៨នាក់ ថ្ងៃទី១៣ ខែកញ្ញា ឆ្នាំ២០១៦ ។<br>• នៅសាលាឃុំសេនារាជឧត្តម ស្រុកព្រះស្តេច មានអ្នកចូលរួមចំនួន១០២នាក់ ស្រីចំនួន៧៥នាក់ ថ្ងៃទី១៤ ខែកញ្ញា ឆ្នាំ២០១៦ ។<br>• នៅវត្តសិម្ពលី ភូមិសម្ពលី ឃុំស្តៅកោង ស្រុបាភ្នំ មានអ្នកចូលរួមចំនួន១០៤នាក់ ស្រីចំនួន៧០នាក់ ថ្ងៃទី១៥ ខែកញ្ញា ឆ្នាំ២០១៦ ។<br>-នៅភូមិស្តៅកោង ឃុំស្ពឺក ស្រុកបាភ្នំ មានអ្នកចូលរួមចំនួន១០៥នាក់ ស្រីចំនួន៧១នាក់ ថ្ងៃទី២០ ខែកញ្ញា ឆ្នាំ២០១៦ ។ |
| ខេត្តស្វាយរៀង | - ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីច្បាប់បង្ក្រាបអំពើជួញដូរមនុស្ស និងការធ្វើអាជីកម្មទេសន្តរប្រវេសន៍ ដល់មន្ត្រីនគរបាល នាយប៉ុស្តិ៍នគរបាល ស្រុកស្វាយទាប ក្រុងបាវិត ចំនួន០២វគ្គ មានអ្នកចូលរួមចំនួន៥៤នាក់(ប្រុស)។<br>- ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមវគ្គបណ្តុះបណ្តាល ស្តីពីការពង្រឹងសមត្ថភាព ចំណេះដឹងយេនឌ័រ និងការពារសិទ្ធិកុមារ ការរំលោភបំពានផ្លូវភេទលើកុមារ ដល់កងកម្លាំងនគរបាលរាជធានី/ខេត្ត បានចំនួន០១វគ្គ មានអ្នកចូលរួមចំនួន៣១នាក់ ស្រីចំនួន១៥នាក់ ។<br>- ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំកិច្ចប្រជុំ ស្តីពីការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សប្រចាំត្រីមាសទី៣ ទិសដៅត្រីមាសទី៤ ឆ្នាំ២០១៦ នៅសាលប្រជុំសាលាខេត្ត ដោយមានកិច្ចសហការគាំទ្រពីអង្គការ សន្តិសេនា ។ |
| ខេត្តកំពត | - គណៈកម្មាធិការ គ.ខ.ប.ជ បានប្រជុំលេខាធិការដ្ឋាន ខេត្ត និងក្រុមការងារទាំង៦ ដើម្បីត្រួតពិនិត្យការអនុវត្តការងារបន្តនិរន្តភាព ក្នុងការដឹកនាំគ្រប់គ្រង និងជំរុញឲ្យក្រុមការងារខិតខំប្រឹងប្រែងយកចិត្តទុកដាក់ ក្នុងការគ្រប់គ្រងសភាពការណ៍បទល្មើសគ្រប់មុខសញ្ញា ការបង្ការទប់ស្កាត់រាល់បណ្តាសកម្មភាពបទល្មើស និងការអប់រំផ្សព្វផ្សាយដល់ប្រជាជន ឲ្យយល់ជ្រួតជ្រាបអំពីល្បិចកលរបស់ជនល្មើស ធ្វើយ៉ាងណាឲ្យជៀសផុតពីការគ្រោះថ្នាក់ដោយអំពើជួញដូរមនុស្ស ។<br>- គណៈកម្មាធិការ គ.ខ.ប.ជ ខេត្ត បាន ប្រជុំលេខាធិការដ្ឋាន និងក្រុមការងារទាំង៦ ដើម្បីត្រួតពិនិ |

| | |
|---|---|
| | ត្យការអនុវត្តការងារដឹកនាំ គ្រប់គ្រង និងជំរុញឲ្យមន្ត្រីក្រោមឱវាទ ខិតខំប្រឹងប្រែងយកចិត្តទុកដាក់ក្នុងការតាមដានសភាព ការបទល្មើសគ្រប់មុខសញ្ញា ការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស ទប់ស្កាត់ការធ្វើចំណាកស្រុកខុសច្បាប់ និងការងារអប់រំផ្សព្វផ្សាយដល់ប្រជាជន នៅតាមមូលដ្ឋាន និងសិស្សានុសិស្សតាមសាលារៀន ឲ្យយល់ជ្រួតជ្រាបអំពីល្បិចកលរបស់ជនល្មើស ។<br>- ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមសិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងមន្ត្រីសង្គមកិច្ច និងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស ,អំពើជួញដូរផ្លូវភេទនិងបទដ្ឋានអប្បរមា សម្រាប់ការថែទាំជនរងគ្រោះ ដែលស្នាក់នៅក្នុងមណ្ឌល និងឧបត្ថម្ភដល់សមាជិក សមាជិកា ដែលបានចំនួន០២លើក នៅខេត្តសៀមរាប និងខេត្តបាត់ដំបង ។ |
| ខេត្តតាកែវ | -លោកស្រីប្រធានលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមប្រជុំគណៈបញ្ជាការឯកភាពរដ្ឋបាលខេត្តប្រចាំខែ សីហា ឆ្នាំ២០១៦ លើការងារសន្តិសុខសណ្តាប់ធ្នាប់សាធារណៈ និងការទប់ស្កាត់អំពើជួញដូរមនុស្ស ដល់សមាជិក សមាជិកា ដែលបានចូលរួមចំនួន៦២នាក់ ស្រីចំនួន០៨នាក់ នៅសាលប្រជុំសាលាខេត្តតាកែវ ។<br>-ក្រុមលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានចូលរួមសិក្ខាសាលា ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការ រវាងមន្ត្រីសង្គមកិច្ច និងមន្ត្រីនគរបាលយុត្តិធម៌ ក្នុងការជួយជនរងគ្រោះដោយអំពើជួញដូរមនុស្ស អំពើជួញដូរផ្លូវភេទនិងបទដ្ឋានអប្បបរមា សម្រាប់ការថែទាំជនរងគ្រោះ ដែលស្នាក់នៅក្នុងមណ្ឌល និងឧបត្ថម្ភដល់សមាជិក សមាជិកាដែលបានចំនួន០២លើក នៅខេត្តសៀមរាប និងខេត្តបាត់ដំបង ។ |

## ឃ. ការលើកកម្ពស់សមត្ថភាព

### ឃ.១.ការបណ្តុះបណ្តាលសមត្ថភាព

ក្នុងត្រីមាសទី៣ ឆ្នាំ២០១៦នេះ ដោយមានការសហការជាមួយអង្គការដៃគូ អគ្គលេខាធិការដ្ឋាន ក៏ដូចជាលេខាធិការដ្ឋានរាជធានី-ខេត្ត បានធ្វើការបណ្តុះបណ្តាលដល់សិក្ខាកាមជាមួយក្រុមប្រឹក្សាឃុំ មន្ត្រីថ្នាក់មូលដ្ឋាន មន្ត្រីលេខាធិការដ្ឋានខេត្ត ជនបង្គោល គ្រូបង្គោលណែនាំតម្រង់ទិសមុនចេញដំណើរ មន្ត្រីអនុវត្តន៍ច្បាប់ លោកគ្រូ អ្នកគ្រូ និងបុគ្គលិកអង្គការ និងប្រតិបត្តិករទេសចរណ៍ នៅតាមសណ្ឋាគារ បានចំនួន៣៣វគ្គ សរុបមានអ្នកចូលរួមចំនួន១,១១១នាក់ (ស្រី៥៥២នាក់) ក្នុងនោះមានខាងក្រោមៈ

+ ខេត្តស្វាយរៀង
- ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការទំនាក់ទំនងដើម្បីអភិវឌ្ឍន៍ និងការផ្លាស់ប្តូរអាកប្បកិរិយា ក្នុងការបង្ការទប់ស្កាត់អំពើជួញដូរមនុស្ស និងនិងក្រុមការងារទទួលបន្ទុកស្រុក ភូមិ ឃុំ ចំនួន០៣វគ្គ មានអ្នកចូលរួមចំនួន២៦នាក់ ស្រីចំនួន២០នាក់ នៅសាលប្រជុំសាលាខេត្តស្វាយរៀង មានការគាំទ្រដោយអង្គការ IOM ។

+ ខេត្តកំពង់ឆ្នាំង
- មន្ទីរកិច្ចការនារីបានបើកវគ្គបណ្តុះបណ្តាល ស្តីពីសិទ្ធិកុមារ និងការធ្វើចំណាកស្រុក បានចំនួន០២វគ្គ មានអ្នកចូលរួមចំនួន៧៩នាក់ ស្រីចំនួន៤៨នាក់ ។

+ ខេត្តព្រៃវែង

ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានបើកវគ្គបណ្តុះបណ្តាល ស្តីពីការធ្វើចំណាក ស្រុក

ដោយសុវត្ថិភាពដល់ថ្នាក់ដឹកនាំភូមិ ឃុំ ស្រុក និងប៉ុស្តិ៍នគរបាលបានចំនួន០៥វគ្គ មានអ្នកចូលរួមចំនួន ១០២នាក់ ស្រីចំនួន១២នាក់ ។

+ខេត្តកំពង់ចាម ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ស.ប.ជ ស្រុក បានបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស បានចំនួន០១វគ្គ ចំនួន០២ថ្ងៃ នៅស្រុកចម្ការលើ មានអ្នកចូលរួមចំនួន ៤៦នាក់ ស្រីចំនួន២៥នាក់ នៅសាលប្រជុំសាលាខេត្ត មានការឧបត្ថម្ភគាំទ្រថវិកាដោយអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រី និងកុមារ ។

+ខេត្តសៀមរាប

-ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ស.ប.ជ ស្រុក បានបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ បានចំនួន០១វគ្គ មានអ្នកចូលរួមចំនួន៥២នាក់ ស្រីចំនួន២៣នាក់ ។

-សាខាកាកបាតក្រហមខេត្តសៀមរាប បានបើកវគ្គបណ្តុះបណ្តាល ស្តីពីពិការភាព ក្នុងការងារសុវត្ថិភាពចរាចរណ៍ និងបានផ្សព្វផ្សាយច្បាប់ ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើអាជីវកម្មផ្លូវភេទ ដល់មន្ត្រីប្រចាំការអនុសាខាកាកបាតក្រហមឃុំ សង្កាត់ ទីប្រឹក្សាយុវជន យុវជនកាកបាតក្រហមកម្ពុជា បានចំនួន១៣លើក ដែលមានអ្នកចូលរួមចំនួន ៥៤៦នាក់ ស្រីចំនួន៣១២នាក់ ក្នុងនោះ(ពិការភាពចំនួន ២៥នាក់ ស្រីចំនួន០៩នាក់) ក្នុងគោលបំណងផ្តល់ចំណេះ ដឹង ដើម្បីក្លាយជាគ្រូបង្គោលអប់រំផ្សព្វផ្សាយបន្តដល់ប្រជាពលរដ្ឋក្នុងសហគមន៍ និងសិស្សានុសិស្សតាមសាលារៀន ។

-រដ្ឋបាលស្រុកជីក្រែងបានសហការជាមួយអង្គការ IOM បើកវគ្គបណ្តុះបណ្តាលគ្រូបង្គោលគាំទ្រចិត្តសាស្ត្រសង្គម ស្តីពី ការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ដល់សហគមន៍ជនរងគ្រោះដោយអំពើជួញដូរមនុស្ស បានចំនួន០១លើក រយៈពេល០៣ថ្ងៃ ដែលមានក្រុមប្រឹក្សាឃុំ កិច្ចការនារីឃុំ នគរបាលប៉ុស្តិ៍ មេភូមិ និងព្រះសង្ឃ ចូលរួមចំនួន៣១នាក់ ។

-មន្ទីរអប់រំយុវជន និងកីឡាខេត្ត បានបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ ដល់មន្ត្រីការិយាល័យអប់រំយុវជន និងកីឡាទាំង១២ក្រុង ស្រុក ព្រមទាំងតាមវិទ្យាល័យមួយចំនួន បានចំនួន០១វគ្គ ។

+ខេត្តកណ្តាល លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានសហការជាមួយអគ្គលេខាធិការ គ.ជ.ប.ជ បើកវគ្គបណ្តុះបណ្តាលដល់មន្ត្រីថ្នាក់ខេត្ត ក្រុង/ស្រុក និងក្រុមការងារទាំង៦របស់ខេត្ត ស្តីពីការកំណត់អត្តសញ្ញាណជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដើម្បីផ្តល់សេវាសមស្រប បានចំនួន០១វគ្គរយៈពេល០៣ថ្ងៃ មានអ្នកចូលរួមចំនួន៧២នាក់ ស្រីចំនួន៣៥នាក់

+ខេត្តស្វាយរៀង ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានបើកវគ្គបណ្តុះបណ្តាលគោលការណែនាំ ស្តីពីការការថែទាំជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដល់ថ្នាក់ដឹកនាំសហគមន៍ក្នុងស្រុកកំពង់រោទិ៍ ស្រុកស្វាយទាប និងក្រុងបាវិត បានចំនួន០៣វគ្គ មានអ្នកចូលរួមចំនួន៧៨នាក់ ស្រីចំនួន៣៥នាក់ នៅសាលប្រជុំសាលាខេត្តស្វាយរៀង មានការគាំទ្រដោយអង្គការ IOM ។

+ខេត្តកំពង់ចាម

ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ស.ប.ជ ស្រុក បានបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការបង្ក្រាបអំពើ

ជួញដូរមនុស្ស បានចំនួន០១វគ្គ ចំនួន០២ថ្ងៃ នៅស្រុកចំការលើ មានអ្នកចូលរួមចំនួន៤៦នាក់ ស្រីចំនួន២៥នាក់នៅសាលាខេត្តមានការឧបត្ថម្ភគាំទ្រថវិកាដោយអង្គការជំនួយផ្លូវច្បាប់ដល់ស្ត្រី និងកុមារ ។

+ ខេត្តកំពង់ធំ

- ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ស.ប.ជ ខេត្ត បានបើកវគ្គបណ្តុះបណ្តាលច្បាប់ ស្តីពីការបង្ក្រាទប់ស្កាត់អំពើជួញដូរមនុស្ស ការរំលោភបំពានផ្លូវភេទ ការកេងប្រវ័ញ្ចផ្លូវភេទ និងការប្រើអំពើហិង្សាដល់កុមារ បានចំនួន០១វគ្គ មានអ្នកចូលរួមចំនួន៣០នាក់ ស្រីចំនួន១៧នាក់ ។

### គ.២.សិក្ខាសាលា

ក្នុងត្រីមាសទី៣ ឆ្នាំ២០១៦ដោយមានការសហការជាមួយអង្គការដៃគូ អគ្គលេខាធិការដ្ឋាន ក៏ដូចជាលេខាធិការដ្ឋានរាជធានី-ខេត្ត បានរៀបចំ និងចូលរួមសិក្ខាសាលាផ្តោតលើប្រធានបទសំខាន់ៗដែលជាកិច្ចការអាទិភាពទាក់ទងនឹងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្សបានចំនួន០៤លើក មានអ្នកចូលរួមចំនួន២០៥នាក់ ស្រីចំនួន៩៤នាក់ មានដូចខាងក្រោម ៖

+ ខេត្តបាត់ដំបង

- មន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈបានរៀបចំសិក្ខាសាលាផ្សព្វផ្សាយអនុក្រឹត្យលេខ ១៩០ របស់រាជរដ្ឋាភិបាល និងប្រកាសបំពេញបន្ថែមចំនួន០៨ របស់ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈស្តីពីការគ្រប់គ្រងលើការបញ្ជូនពលករខ្មែរទៅធ្វើការនៅបរទេស តាមរយៈទីភ្នាក់ងារជ្រើសរើសឯកជនបានចំនួន០១លើក មាននចំនួន០៥ស្រុក (ស្រុកសង្កែ ស្រុកបាណន់ ស្រុកថ្មគោល ស្រុកឯកភ្នំ និងក្រុងបាត់ដំបង ) មានអ្នកចូលរួមសរុប៧៩នាក់ ស្រីចំនួន៣៩នាក់ ។

+ ខេត្តតាកែវ ក្រុមការងារលេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំសិក្ខាសាលាបណ្តាញសុវត្ថិភាព ស្តីពីវិធានការបង្ការ-ទប់ស្កាត់ប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងការធ្វើចំណាកស្រុកប្រកបដោយសុវត្ថិភាពបានចំនួន០២លើក ដែលមានការចូលរួមពីមន្ទីរសុខាភិបាលខេត្ត និងក្រុមការងារនៅស្រុព្រៃកប្បាស ដែលមានអ្នកចូលរួមសរុប១០៥នាក់ ស្រីចំនួន៤៧នាក់ មានការគាំទ្រដោយអង្គការ VCAO ។

+ខេត្តស្វាយរៀង ក្រុមការងាររបស់លេខាធិការដ្ឋាន គ.ខ.ប.ជ ខេត្ត បានរៀបចំសិក្ខាសាលាថ្នាក់ខេត្ត ស្តីពីការប្រយុទ្ធប្រឆាំងនឹងពលកម្មកុមារ ដល់ក្រុមការងារថ្នាក់ខេត្ត បានចំនួន០១លើក មានអ្នកចូលរួមចំនួន២១នាក់ ស្រីចំនួន០៨នាក់ នៅសាលប្រជុំសាលាខេត្តស្វាយរៀង មានកិច្ចសហការគាំទ្រដោយអង្គការសន្តិសេនា ។

## ៣.សន្និដ្ឋាន និងការវាយតម្លៃ

- រាជរដ្ឋាភិបាលកម្ពុជាបានប្តេជ្ញាចិត្តខ្ពស់ ចំពោះការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស និងពង្រឹងរបៀបរបបការងារទំនាក់ទំនង សហប្រតិបត្តិការរវាងក្រសួង ស្ថាប័ន អង្គភាពពាក់ព័ន្ធ ឆ្ពោះទៅកាន់គោលដៅរួមតែមួយ តាមរយៈការបង្កើតគណៈកម្មាធិការជាតិ ដែលមានសមាសភាពចម្រុះក្រសួង ស្ថាប័ន ដើម្បីជាការរួមបញ្ចូលនូវកិច្ចខិតខំប្រឹងប្រែងរួមជាពហុវិស័យ ក្រោមរចនាសម្ព័ន្ធដ៏ទូលំទូលាយ តាំងពីថ្នាក់ជាតិ ថ្នាក់ក្រោមជាតិ និងជាមួយអន្តរជាតិ។

- ព្រះរាជាណាចក្រកម្ពុជា មានច្បាប់ស្តីពីការបង្ក្រាបអំពើជួញដូរមនុស្ស និងអំពើធ្វើអាជីវកម្មផ្លូវភេទ ក្រមនីតិវិធីព្រហ្មទណ្ឌ និងក្រមព្រហ្មទណ្ឌត្រូវបានអនុវត្ត ព្រមទាំងបានបង្កើតនូវបទដ្ឋានគតិយុត្តិមួយចំនួនទៀត ដើម្បីបំពេញបន្ថែមលើការខ្វះខាត និងសម្រួលដល់ការអនុវត្តឲ្យរឹតតែមានប្រសិទ្ធភាពទ្បើងថែមទៀត។
- មានយុទ្ធសាស្ត្រទូលំទូលាយ ដើម្បីការបង្ការទប់ស្កាត់ ការបង្ក្រាប ការផ្តន្ទាទោសជនល្មើស និងការការពារជនរងគ្រោះ ដោយមានសេវាស្តារនីតិសម្បទា សមាហរណកម្ម និងមាតុភូមិនិវត្តន៍ ព្រមទាំងការពង្រឹងកិច្ចសហការជាមួយបណ្តាប្រទេសពាក់ព័ន្ធ ជាទ្វេភាគី និងជាពហុភាគី ដើម្បីប្រឆាំងការជួញដូរមនុស្ស និងបានគិតគូជាពិសេសចំពោះការការពារសិទ្ធិ និងឧត្តមប្រយោជន៍របស់ស្ត្រី និងកុមារ។
- មានអគ្គលេខាធិការដ្ឋាន ជាសេនាធិការ ដើម្បីទំនាក់ទំនងសម្របសម្រួលជាមួយគ្រប់ស្ថាប័ន និងភាគីពាក់ព័ន្ធ ជាកម្លាំងចម្រុះពហុវិស័យ កម្លាំងសរុបធនធានសរុប និងមធ្យោបាយសរុប ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ សំដៅឆ្លើយតបទៅនឹងអំពើជួញដូរមនុស្សបានទាន់ពេលវេលា និងមានប្រសិទ្ធភាពខ្ពស់ ។
- គោលនយោបាយភូមិ-ឃុំមានសុវត្ថិភាព របស់រាជរដ្ឋាភិបាល ដែលមានក្រសួងមហាផ្ទៃជាស្នូល គឺជាកម្លាំងចលករយ៉ាងសំខាន់បំផុតក្នុងការបំផុសការចូលរួមពីមូលដ្ឋាន ដើម្បីការពារសន្តិសុខ និងសុវត្ថិភាពរបស់ប្រជាពលរដ្ឋ និងចូលរួមអនុវត្តសកម្មភាពបង្ការ ទប់ស្កាត់ ការអនុវត្តច្បាប់ និងការជួយជនរងគ្រោះដែលមានក្នុងមូលដ្ឋាននីមួយៗ។
- រាជរដ្ឋាភិបាល អង្គការជាដៃគូជាតិ និងអន្តរជាតិ បានគាំទ្រទាំងស្មារតី និងថវិកា ដើម្បីផ្តល់លទ្ធភាពឲ្យក្រសួង មន្ទីរ ស្ថាប័នពាក់ព័ន្ធ ទាំងនៅថ្នាក់ជាតិ ទាំងថ្នាក់ក្រោមជាតិ បំពេញភារកិច្ចតាមការកំណត់ និងធ្វើឲ្យសម្រេចផែនការជាតិដែលបានឯកភាពគ្នា។
- រាជរដ្ឋាភិបាល មានគោលនយោបាយសេដ្ឋកិច្ច និងប្រព័ន្ធស្វែងរកការងារស្របច្បាប់ និងគោលនយោបាយសេវាសង្គម ក្នុងការបង្កើនឱកាសការងារ និងកាត់បន្ថយភាពក្រីក្ររបស់ប្រជាពលរដ្ឋ។

ក្រោយពីបានបូកសរុបរបាយការណ៍សកម្មភាព និងលទ្ធផលការងារប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ត្រីមាសទី៣ ឆ្នាំ២០១៦ នៃគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) យើងអាចធ្វើការសន្និដ្ឋានបានថាអំពើជួញដូរមនុស្ស ការកេងប្រវ័ញ្ចកម្លាំងពលកម្ម និងអំពើជួញដូរផ្លូវភេទលើស្ត្រី និងកុមារនៅក្នុងព្រះរាជាណាចក្រកម្ពុជា មានការថយចុះបើប្រៀបធៀបត្រីមាសទី១ ឆ្នាំ២០១៥កន្លងទៅ ជាពិសេសប្រជាពលរដ្ឋ មានការយល់ដឹងខ្ពស់អំពីការធ្វើចំណាកស្រុកខុសច្បាប់ និងយល់ដឹងអំពីល្បិចកលរបស់មេខ្យល់ ឬជនឆបោកមួយចំនួន បន្ទាប់ពីមានការបណ្តុះបណ្តាលពីគណៈកម្មាធិការជាតិ គ.ជ.ប.ជ និងបានធ្វើការអប់រំផ្សព្វផ្សាយបន្តពីលេខាធិការដ្ឋាន រាជធានី-ខេត្តទៅដល់ប្រជាពលរដ្ឋផ្ទាល់នៅតាមមូលដ្ឋាន។

ក្នុងត្រីមាសទី៣ ឆ្នាំ២០១៦ គឺជាឆ្នាំនៃការកសាងមូលដ្ឋានគ្រឹះ សម្រាប់ការពង្រឹងគណៈកម្មាធិការជាតិ និងប្រសិទ្ធភាពការងារ ។

## ៣.១.ចំណុចខ្លាំង

តាមរយៈការខិតខំប្រឹងប្រែងក្នុងត្រីមាសទី៣ ឆ្នាំ២០១៦នេះ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ សម្រេចបានការងារ ជាលទ្ធផលជោគជ័យគួរឲ្យកត់សម្គាល់៖

១. បានប្រកាសជាផ្លូវការ គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ គណៈកម្មាធិការរាជធានី-ខេត្ត គ.រ.ប.ជ/គ.ខ.ប.ជ លេខាធិការដ្ឋាន គ.រ.ប.ជ/គ.ខ.ប.ជ ប្រកាសសេចក្តីសម្រេចកំណត់តួនាទី និងភារកិច្ច រួចជាស្រេច។

២. បានដាក់ចុះផែនការសកម្មភាពជាតិ របស់គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស (គ.ជ.ប.ជ) សម្រាប់រយៈពេល៥ឆ្នាំ (២០១៤-២០១៨) ជាផែនទីបង្ហាញផ្លូវ។

៣. បានរៀបចំក្រុមការងារអគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ នឹងបន្តសកម្មភាពដឹកនាំជាយុទ្ធសាស្ត្រ របស់ក្រុមការងារទាំង៦ និងថ្នាក់ក្រោមជាតិ ព្រមទាំងពង្រឹងកិច្ចសហប្រតិបត្តិការរួមគ្នា លើកវិធានការ ការងារបង្ការទប់ស្កាត់ និងបង្ក្រាបបទល្មើសជួញដូរមនុស្ស។

៤. បានបង្កើនកិច្ចសហប្រតិបត្តិការ ជាមួយអន្តរក្រសួង ស្ថាប័ននានា ក្នុងដំណើរការសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៥. កិច្ចខិតខំប្រឹងប្រែងរបស់ក្រុមការងារអនុវត្តន៍ច្បាប់ ដែលបានអនុវត្តទៅតាមតួនាទី និងភារកិច្ចដែលបានដាក់ចុះសម្រេចបាននូវលទ្ធផលគួរឲ្យកត់សម្គាល់។

៦. បានខិតខំស្វែងរកការគាំទ្រ និងកិច្ចសហការពីអង្គការជាតិ អន្តរជាតិ ជាដៃគូនានា សំដៅអនុវត្តសកម្មភាពប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ឲ្យកាន់តែមានប្រសិទ្ធភាព។

## ៣.២.ចំណុចខ្វះខាត និងបញ្ហាប្រឈម

ទន្ទឹមនឹងការខិតខំប្រឹងប្រែង ជាចំណុចខ្លាំងខាងលើ ក៏នៅមានចំណុចសេសសល់និងប្រឈមមួយចំនួនៈ

- ពង្រឹងបន្ថែមសមត្ថភាព ធនធាន សម្ភារៈ ឧបករណ៍ និងបច្ចេកទេសមួយចំនួន ដែលចាំបាច់សម្រាប់ការអនុវត្តច្បាប់ ដើម្បីឆ្លើយតបទៅនឹងសភាពការណ៍បទល្មើស ភាពជឿនលឿន នៃវិទ្យាសាស្ត្រ និងជាពិសេស សម្រាប់សមាសភាពមន្ត្រី ដែលមានការផ្លាស់ប្តូរថ្មី និងដែលមិនទាន់ទទួលការបណ្តុះបណ្តាល ។
- កិច្ចសហការពីអ្នកពាក់ព័ន្ធ និងលទ្ធភាពក្នុងការសង្គ្រោះ និងជួយគាំពារជនរងគ្រោះ នៅមិនទាន់ឆ្លើយតបនឹងតម្រូវការ ។
- ការទទួលព័ត៌មាន និងការអប់រំផ្សព្វផ្សាយ អំពីកលល្បិចរបស់ជនខិលខូចនៅមិនទាន់បានទូលំទូលាយនៅឡើយសម្រាប់ប្រជាពលរដ្ឋ ជាពិសេសប្រជាពលរដ្ឋ ដែលរស់នៅតំបន់ជនបទដាច់ស្រយ៉ាលដែលជាចំណុចចន្លោះប្រហោងមួយ សម្រាប់ពួកឈ្មួញទុច្ចរិតធ្វើការអូសទាញបោកបញ្ឆោតទាំង បុរស ស្ត្រី និងកុមារ ឲ្យជឿជាក់ និងធ្វើតាម។
- ជីវភាពរស់នៅរបស់ប្រជាពលរដ្ឋមានការប្រែប្រួល មិនមានស្ថេរភាព ចំណេះដឹងនិងការអប់រំ ក៏នៅមានកម្រិតទាប ដែលជាហេតុនាំឲ្យពួកគាត់ ធ្វើការសម្រេចចិត្តដោយខ្វះការពិចារណា តាមការអូសទាញរបស់ជនទុច្ចរិត។
- គណៈកម្មាធិការរាជធានី/ខេត្ត និងលេខាធិការដ្ឋានថ្នាក់ក្រោមជាតិមួយចំនួន នៅមិនទាន់បានរៀបចំច្បាស់លាស់ ក្នុងការអនុវត្ត និងតាមដានការងារជាប្រចាំ និងខេត្តខ្លះពុំទាន់មានថវិកា សម្រាប់ចំណាយលើសកម្មភាព ។
- អង្គការជាតិ និងអន្តរជាតិមួយចំនួន នៅមិនទាន់ចូលរួមសហការ ពេញលេញ និងជាក់លាក់ ក្នុងការអនុវត្តសកម្មភាពរួមគ្នា ជាមួយគណៈកម្មាធិការជាតិ គ.ជ.ប.ជ ។

- ខ្ះការតាមដានត្រួតពិនិត្យឲ្យបានច្បាស់លាស់ចំពោះក្រុមហ៊ុន ដែលទទួលបានសិទ្ធិអនុញ្ញាតជ្រើសរើសពលករទៅធ្វើការងារនៅបរទេស ជៀសវាងភាពមិនប្រក្រតីណាមួយកើតមានឡើង។
- កិច្ចសហការរបស់ក្រសួង ស្ថាប័នដែលមានសមត្ថកិច្ចពាក់ព័ន្ធ ចាំបាច់ត្រូវពង្រឹងបន្ថែម ដើម្បីធ្វើការត្រួតពិនិត្យលើក្រុមហ៊ុនជ្រើសរើសពលករ និងជំរុញឲ្យអនុវត្តវិធានការ គោលការណ៍ណែនាំ គោលនយោបាយ និងច្បាប់ ព្រមជាមួយនឹងការចាត់វិធានការជាក់ស្តែង ដោយធ្វើការអប់រំ ណែនាំ ព្រមាន និងផ្តន្ទាទោសតាមច្បាប់ចំពោះភ្នាក់ងារក្រុមហ៊ុនខិលខូច ឬអ្នកប្រព្រឹត្តបទល្មើសផ្ទុយពីគោលការណ៍ណែនាំ និងនីតិវិធីទាំងនោះ។

## ៤.ទិសដៅសម្រាប់ត្រីមាសទី៤ ឆ្នាំ២០១៦

គណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស បានធ្វើការប្រជុំពិភាក្សាលើកទិសដៅការងារសម្រាប់អនុវត្តបន្តត្រីមាសទី៤នៅឆ្នាំ២០១៦ មានដូចខាងក្រោម ៖

១. ជំរុញការអនុវត្តអនុសាសន៍ដ៏ខ្ពង់ខ្ពស់ ០៤ចំណុចរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ថ្លែងក្នុងទិវាជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស ១២ ធ្នូ ឆ្នាំ២១០១៥ នៅសាលមហោស្រព នៃមជ្ឈមណ្ឌលសន្និបាត និងពិព័រណ៍កោះពេជ្រ រាជធានីភ្នំពេញ និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាល លេខ០០១ គកន ចុះថ្ងៃទី២៥ ខែកក្កដា ឆ្នាំ២០១៣ ស្តីពីការគ្រប់គ្រងកម្លាំងពលកម្ម និងលំហូរទេសន្តរប្រវេសន៍។

២ បន្តជំរុញអនុវត្ត វិធានការ ០៦ចំណុច របស់**សម្តេចក្រឡាហោម ស ខេង ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រីក្រសួងមហាផ្ទៃ ប្រធានគណៈកម្មាធិការជាតិប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស**។

៣. រៀបចំសកម្មភាពវាយតម្លៃផែនការសកម្មភាពជាតិ ២០១៤-២០១៨ ពាក់កណ្តាលអាណត្តិ និងកែលម្អសកម្មភាពជំហានបន្តរហូតដល់ឆ្នាំ២០១៨។

៤. រៀបចំសកម្មភាពបណ្តុះបណ្តាលមន្ត្រី ពាក់ព័ន្ធ នឹងការកំណត់អត្តសញ្ញាណជនរងគ្រោះនៅតាមបណ្តាក្រសួង ស្ថាប័ន អង្គការដៃគូក្នុងស្រុក និងមន្ត្រីប្រចាំស្ថានទូតកម្ពុជា ក្នុងប្រទេសគោលដៅ និងជំរុញការអនុវត្តបន្ត។

៥. ត្រៀមសេចក្តីព្រាងផែនការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ចិន ស្តីពីការពង្រឹងកិច្ចសហប្រតិបត្តិការបង្ការទប់ស្កាត់និងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

៦. ធ្វើការស្រាវជ្រាវ អំពីកាលានុវត្តភាពការងារជាជម្រើសរបស់ពលករកម្ពុជាក្នុង និងក្រៅប្រទេស និងស្វែងយល់ពីកក្តារុញច្រាននិងអូសទាញដើម្បីរៀបចំផែនការបង្ការទប់ស្កាត់។

៧. ត្រៀមកិច្ចប្រជុំទ្វេភាគីកម្ពុជា-ចិន ដើម្បីពិនិត្យសម្រេចលើសេចក្តីព្រាងកិច្ចព្រមព្រៀង ដែលបានឯកភាពគ្នាជាគោលការណ៍រួចហើយកាលពីជំនួបនៅប្រទេសចិននាខែវិច្ឆិកាឆ្នាំ២០១៥។

៨. ត្រៀមពិនិត្យកិច្ចព្រមព្រៀងទ្វេភាគីកម្ពុជា-ឥណ្ឌាតាមការស្នើសុំរបស់រដ្ឋាភិបាលឥណ្ឌា។

៩. ត្រៀមកិច្ចប្រជុំពិគ្រោះយោបល់រវាងក្រុមប្រទេសបញ្ជូន និងប្រទេសទទួល(ថៃ ម៉ាឡេស៊ី..) ដើម្បីពង្រឹងកិច្ចសហការដើម្បីចែករំលែកការទទួលខុសត្រូវនិងការពារផលប្រយោជន៍ពលករ និយោជក និងរវាងប្រទេសបញ្ជូននិងប្រទេសទទួលប្រកបដោយសមធម៌។

១០.បន្តពង្រឹងកិច្ចសហការទូលំទូលាយឆ្ពោះទៅកាន់គោលដៅរួម គឺការបង្ការទប់ស្កាត់ឈានទៅលុបបំបាត់អំពើជួញដូរមនុស្ស ក្នុងព្រះរាជាណាចក្រកម្ពុជា និងទៅលើប្រជាជនកម្ពុជា។

១១.ជំរុញការអនុវត្តច្បាប់គោលនយោបាយ និងបទដ្ឋានគតិយុត្តនានាទៅតាមមុខសញ្ញា នៃក្រសួងស្ថាប័ន និងអង្គភាពដែលទទួលខុសត្រូវ ឈានទៅធ្វើឲ្យសម្រេចគោលដៅរបស់រាជរដ្ឋាភិបាល ក្នុងការប្រយុទ្ធប្រឆាំងអំពើជួញដូរមនុស្ស។

១២.សម្របសម្រួលពង្រឹង និងពង្រីកកិច្ចសហការឲ្យបានទូលំទូលាយជាមួយគ្រប់ផ្នែកគ្រប់វិស័យ និងរវាងរាជរដ្ឋាភិបាល និងដៃគូពាក់ព័ន្ធអង្គការជាតិ និងអន្តរជាតិសង្គមស៊ីវិលផ្នែកឯកជនដើម្បីអនុវត្តយុទ្ធសាស្ត្រដែលបានគ្រោងទុកក្នុងផែនការជាតិផែនការក្រុម និងផែនការរាជធានី/ខេត្ត។

១៣.គាំទ្រនិងពង្រឹងសមត្ថភាពរបៀបរបបការងាររបស់ក្រុមការងារ និងលេខាធិការដ្ឋានរាជធានី/ខេត្ត។

១៤.បន្តការងារផ្សព្វផ្សាយអប់រំតាមគ្រប់រូបភាព និងប្រើគ្រប់លទ្ធភាព និងធនធានដើម្បីលើកកម្ពស់ការយល់ដឹងជាសកលអំពីការជួញដូរមនុស្ស ការធ្វើអាជីវកម្មផ្លូវភេទ និងការកេងប្រវ័ញ្ចកម្លាំងពលកម្ម ទំនាក់ទំនងរវាងទេសន្តរប្រវេសន៍ និងអំពើជួញដូរមនុស្ស និងបទល្មើសពាក់ព័ន្ធដទៃទៀតឲ្យបានដល់ប្រជាពលរដ្ឋជាពិសេសស្រទាប់យុវវ័យ និងជនដែលងាយរងគ្រោះ។

១៥.បន្តតាមដានលទ្ធផលនិងប្រសិទ្ធភាពនៃការអនុវត្តកិច្ចព្រមព្រៀងទ្វេភាគីពហុភាគីនិងគាំទ្រដល់ការអនុវត្តអនុសញ្ញាអាស៊ានប្រឆាំងការជួញដូរមនុស្ស ដែល**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីព្រះរាជាណាចក្រកម្ពុជា** ទើបតែចុះហត្ថលេខារួមគ្នា កាលពីខែវិច្ឆិកាឆ្នាំ២០១៥។

១៦. ជំរុញតាមដានត្រួតពិនិត្យក្រុមហ៊ុនបញ្ជូនពលករទៅធ្វើការនៅក្រៅប្រទេស ឲ្យអនុវត្តតាមគោលនយោបាយរបស់រាជរដ្ឋាភិបាលឲ្យបានត្រឹមត្រូវ។

១៧. ពិនិត្យលទ្ធភាពក្នុងការផ្តល់សេវាជូនជនរងគ្រោះ បន្តរៀបចំមណ្ឌលរដ្ឋ សម្រាប់ទទួលជនរងគ្រោះដោយអំពើជួញដូរមនុស្ស ដែលបញ្ជូនមកពីក្រៅប្រទេស ។

១៨. បន្តលើកកម្ពស់សមត្ថភាព និងពង្រឹងកិច្ចសហការរវាងមន្ត្រីអនុវត្តន៍ច្បាប់ និងប្រព័ន្ធយុត្តិធម៌ទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិឲ្យមានសមត្ថភាពគ្រប់គ្រាន់ ក្នុងការបង្ក្រាបបទល្មើស និងផ្តន្ទាទោសជនល្មើសតាមផ្លូវច្បាប់ប្រកបដោយប្រសិទ្ធភាពនិងយុត្តិធម៌។

១៩. រៀបចំកិច្ចប្រជុំអន្តរក្រសួង ស្ថាប័ន លើការងារគ្រប់គ្រង ច្រកព្រំដែន ។

២០. បន្តរៀបចំផែនការបណ្តុះបណ្តាលពង្រឹងមន្ត្រីឲ្យមានសមត្ថភាពជំនាញទាំងនៅថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិ។

២១. បន្តគាំទ្រនិងពង្រឹងការអនុវត្តគោលនយោបាយភូមិ/ឃុំមានសុវត្ថិភាពរបស់រាជរដ្ឋាភិបាល ៕

រាជធានីភ្នំពេញ ថ្ងៃទី១៦.........ខែ[illegible]..........ឆ្នាំ២០១៦

**អនុប្រធានអចិន្ត្រៃយ៍ គ.ជ.ប.ជ**

ជូ-ប៊ុនអេង

**ចម្លងជូន**

-ខុទ្ទកាល័យសម្តេចក្រឡាហោមឧបនាយករដ្ឋមន្ត្រីរដ្ឋមន្ត្រីក្រសួងមហាផ្ទៃនិងជាប្រធាន គ.ជ.ប.ជ
"ដើម្បីគោរពជូនជាសេចក្តីរាយការណ៍"
-ឯកឧត្តម លោកជំទាវប្រធានក្រុមការងារជំនាញអន្តរក្រសួង ស្ថាប័ន
-សមាជិកក្រុមការងារ អគ្គលេខាធិការដ្ឋាន គ.ជ.ប.ជ"ដើម្បីជូនជ្រាប"
-ឯកសារ កាលប្បវត្តិ